# ការផ្តួចផ្តើមក្នុងការទទួលយកជនជានមនុស្សបរទេសថ្មីទៀត និងការសម្រេចអោយបាននូវសង្គមមានសហត្ថិភាព

គិតត្រឹមចុងខែមិថុនា ឆ្នាំ2019

出入国在留管理庁
ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

សូមមើលនៅទីនេះសំរាប់ព័ត៌មានចុងក្រោយ (គេហទំព័ររបស់ក្រសួងយុត្តិធម៌)។

ការទទួលយកជនជានមនុស្សបរទេសថ្មី (ការបង្កើតលក្ខណ: សម្បត្តិស្នាក់នៅ “ពលករជំនាញ”)

http://www.moj.go.jp/nyuukokukanri/kouhou/nyuukokukanri01_00127.html

【មាតិកា (ខ្លឹមសារ)】


I បំរែបំរួលនៃចំនួនជនបរទេស្នាក់នៅជប៉ុន………………………………… 1
2 តារាងនៃប្រភេទលក្ខណៈសម្បត្តិស្នាក់នៅ……………………………………… 2
3 បំណែងចែកទៅតាមប្រភេទលក្ខណៈសម្បត្តិស្នាក់នៅនិងទៅតាមសញ្ជាតិនៃជនបរទេសស្នាក់នៅ
(គិតត្រឹមចុងខែមិថុនា ឆ្នាំ2019 ) ……………………………………………… 3
4 បំណែងចែកប្រភេទនៃចំនួនពលករបរទេស…………………………………… 4
5 ការទទួលយកពលករបរទេស ……………………………………………… 5
6 ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (I) អំពីលក្ខណៈសម្បត្តិស្នាក់នៅ…………………………… 6
7 អំពីគោលការណ៍នៃវិស័យនិមួយៗ (I4 វិស័យ)………………………………… 7
8 ការប្រៀបធៀបរវាងប្រព័ន្ធកម្មសិក្សាជំនាញ និងប្រព័ន្ធពលករជំនាញ (ទិដ្ឋភាពទូទៅ)…………… 10
9 ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (2) អំពីស្ថាប័នទទួលនិងស្ថាប័នគាំទ្រចុះបញ្ជី ……………… 11
10 ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (3) លំដាប់លំដោយរហូតដល់ចាប់ផ្តើមការងារ……………… 12
11 ទិដ្ឋភាពទូទៅនៃផែនការគាំទ្រ (I) ……………………………………… 13
12 ទិដ្ឋភាពទូទៅនៃផែនការគាំទ្រ (2) ……………………………………… 14
13 តើអ្វីទៅជាស្ថាប័នគាំទ្រចុះបញ្ជី? ……………………………………… 15
14 អំពីការជូនដំណឹង(ស្ថាប័នទទួល ស្ថាប័នគាំទ្រចុះបញ្ជី) …………………………… 16
15 អំពីគណៈកម្មាធិការនៃវិស័យនិមួយៗរបស់ពលករជំនាញ ………………………… 17
16 ទិដ្ឋភាពទូទៅនៃកិច្ចព្រមព្រៀងទ្វេភាគី (MOC)ទាក់ទងនឹង "ពលករជំនាញ" ……………… 18
17 ស្ថានភាពនៃការអនុវត្តន៍ប្រព័ន្ធពលករជំនាញ ……………………………… 19
18 អំពីគោលការណ៍មូលដ្ឋាន និងបញ្ញត្តិរបស់ក្រសួងមានសមត្ថកិច្ចជាដើម ………………… 21
19 វិធានការគ្រប់ជ្រុងជ្រោយដើម្បីការទទួលយកជនជានមនុស្សបរទេសនិងសហត្ថិភាពក្នុងសង្គម …. 30
20 ឯកសារយោង……………………………………………………… 34

# បំរែបំរួលនៃចំនួនជនបរទេសស្នាក់នៅជប៉ុន




*ចំពោះតួលេខនិមួយៗ ត្រឹមឆ្នាំ2011 គឺចំនួនជនបរទេសចុះបញ្ជី ហើយចាប់ពីឆ្នាំ2012 គឺចំនួនជនបរទេសស្នាក់នៅ។

# តារាងនៃប្រភេទលក្ខណ:សម្បត្តិស្នាក់នៅ

## លក្ខណ:សម្បត្តិស្នាក់នៅអាចធ្វើការបាន (មានការកំណត់សកម្មភាព)

| លក្ខណ:សម្បត្តិស្នាក់នៅ | ឧទាហរណ៍ |
|---|---|
| ការទូត | ឯកអគ្គរាជទូតនៃរដ្ឋាភិបាលបរទេស មន្ត្រីការទូតជាន់ខ្ពស់និងគ្រួសារ |
| ផ្លូវការ | អ្នកធ្វើការផ្លូវការអោយរដ្ឋាភិបាលបរទេសនិងគ្រួសារ។ល។ |
| សាស្ត្រាចារ្យ | សាស្ត្រាចារ្យមហាវិទ្យាល័យ។ល។ |
| សិល្ប: | អ្នកនិពន្ធភ្លេង អ្នកគូរគំនូរ អ្នកនិពន្ធ។ល។ |
| សាសនា | អ្នកផ្សព្វផ្សាយសាសនាដែលត្រូវបានសមាគមសាសនាបរទេសបញ្ជូនមក។ល។ |
| សារព័ត៌មាន | អ្នកយកព័ត៌មាន អ្នកថតរូបនៃស្ថាប័នសារព័ត៌មានបរទេស។ល។ |
| ឯកទេសជាន់ខ្ពស់ | ធនធានមនុស្សកំរិតខ្ពស់ក្រោមប្រព័ន្ធដាក់ពិន្ទុ |
| គ្រប់គ្រង | អ្នកដឹកនាំ អ្នកគ្រប់គ្រងសហគ្រាសជាដើម។ល។ |
| ច្បាប់ សេវាគណនេយ្យ | មេធាវី គណនេយ្យករសាធារណ:ដែលបានបញ្ជាក់ |
| វេជ្ជសាស្ត្រ | វេជ្ជបណ្ឌិត ទន្តបណ្ឌិត គិលានុប្បដ្ឋាក។ល។ |
| ស្រាវជ្រាវ | អ្នកស្រាវជ្រាវនៅក្នុងស្ថាប័នរដ្ឋាភិបាល ឬសហគ្រាស។ល។ |
| អប់រំ | គ្រូបង្រៀនភាសានៅវិទ្យាល័យ អនុវិទ្យាល័យជាដើម។ល។ |
| បច្ចេកវិទ្យា ចំណេះដឹងមនុស្សសាស្ត្រ ការងារអន្តរជាតិ | អ្នកបច្ចេកទេសផ្នែកមេកានិចជាដើម អ្នកបកប្រែភាសា អ្នករចនា គ្រូបង្រៀនភាសា។ល។ |
| ការប្តូរការងារក្នុងសហគ្រាស | អ្នកធ្វើការដែលផ្លាស់មកពីការិយាល័យនៅបរទេស |
| ថែទាំមនុស្ស | អ្នកថែទាំសុខុមាលភាព |
| កំសាន្ត | អ្នកសំដែង អ្នកចំរៀង កីឡាករអាជីព។ល។ |
| ជំនាញ | ចុងភៅម្ហូបបរទេស គ្រូបង្វឹកកីឡា។ល។ |
| ពលករជំនាញ(សំគាល់1) | ពលករធ្វើការនៅគ្រប់ប្រភេទការងារនៃគ្រប់វិស័យរបស់ឧស្សាហកម្មកំណត់(សំគាល់2) |
| កម្មសិក្សាជំនាញ | កម្មសិក្សាការីជំនាញ |

(សំគាល់1) ចាប់ពីថ្ងៃទី1 ខែមេសា ឆ្នាំ2019

(សំគាល់2) ការថែទាំមនុស្ស ការសម្អាតអគារ ឧស្សាហកម្មផលិតគ្រឿងបន្លាស់និងគ្រឿងឧបករណ៍ ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិចនិងព័ត៌មាន ការងារសំណង់ ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា ការជួសជុលរថយន្ត ការងារអាកាសចរណ៍ ការស្នាក់នៅ កសិកម្ម នេសាទនិងវារីវប្បកម្ម ការផលិតអាហារនិងភេសជ្ជ: ឧស្សាហកម្មភោជនីយដ្ឋាន (សម្រេចដោយគណ:រដ្ឋមន្ត្រី នៅថ្ងៃទី25 ខែធ្នូ ឆ្នាំ2018)

## លក្ខណ:សម្បត្តិស្នាក់នៅផ្អែកលើអត្តសញ្ញាណនិងឋាន: (គ្មានការកំណត់សកម្មភាព)

| លក្ខណ:សម្បត្តិស្នាក់នៅ | ឧទាហរណ៍ |
|---|---|
| អ្នកស្នាក់នៅអចិន្ត្រៃយ៍ | អ្នកដែលទទួលបានការអនុញ្ញាតអោយស្នាក់នៅអចិន្ត្រៃយ៍ |
| សហព័ទ្ធ ឬកូនរបស់ជនជាតិជប៉ុនជាដើម | សហព័ទ្ធ កូនបង្កើត កូនចិញ្ចឹមរបស់ជនជាតិជប៉ុន |
| សហព័ទ្ធ ឬកូនរបស់អ្នកស្នាក់នៅ អចិន្ត្រៃយ៍ជាដើម | សហព័ទ្ធរបស់អ្នកស្នាក់នៅអចិន្ត្រៃយ៍ឬអ្នកស្នាក់នៅអចិន្ត្រៃយ៍ពិសេស និងកូនដែលកើតហើយបន្តរស់នៅជប៉ុន |
| អ្នកតាំងលំនៅអចិន្ត្រៃយ៍ | អ្នកជាប់សាច់ឈាមជប៉ុនជំនាន់ទី៣ កូនដើមរបស់សហព័ទ្ធជនជាតិបរទេស។ល។ |

## លក្ខណ:សម្បត្តិស្នាក់នៅសំរាប់សកម្មភាពកំណត់

| លក្ខណ:សម្បត្តិស្នាក់នៅ | ឧទាហរណ៍ |
|---|---|
| សកម្មភាពកំណត់ | អ្នកជួយការងារផ្ទះរបស់មន្ត្រីការទូត ធ្វើការពេលវិស្សមកាល។ល។ |

## លក្ខណ:សម្បត្តិស្នាក់នៅដែលគេមិនអនុញ្ញាតអោយធ្វើការ(*)

| លក្ខណ:សម្បត្តិស្នាក់នៅ | ឧទាហរណ៍ |
|---|---|
| សកម្មភាពវប្បធម៌ | អ្នកស្រាវជ្រាវវប្បធម៌ជប៉ុន។ល។ |
| ការស្នាក់នៅរយ:ពេលខ្លី | ភ្ញៀវទេសចរណ៍ អ្នកចូលរួមប្រជុំ។ល។ |
| និស្សិតបរទេស | សិស្សឬនិស្សិតនៃមហាវិទ្យាល័យ សាលាបណ្តុះបណ្តាលវិជ្ជាជីវ: សាលាភាសាជប៉ុន។ល។ |
| កម្មសិក្សា | កម្មសិក្សាការី |
| ស្នាក់នៅជាមួយគ្រួសារ | សហព័ទ្ធឬកូនរបស់ជនបរទេសដែលស្នាក់នៅដោយមានសិទ្ធិធ្វើការ |

* ក្នុងករណីទទួលបានការអនុញ្ញាតអោយធ្វើសកម្មភាពក្រៅពីអ្វីលក្ខណ:សម្បត្តិស្នាក់នៅ គេអនុញ្ញាតអោយធ្វើការនៅក្នុងព្រំដែនកំណត់មួយ។

# បំណែងចែកទៅតាមប្រភេទលក្ខណៈសម្បត្តិស្នាក់នៅនិងទៅតាមសញ្ជាតិនៃជនបរទេសស្នាក់នៅ

(គិតត្រឹមចុងខែមិថុនា ឆ្នាំ2019)

出入国在留管理庁

ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

## ចំនួនជនបរទេសស្នាក់នៅសរុបៈ 2,829,416

### លក្ខណៈសម្បត្តិស្នាក់នៅ




### សញ្ជាតិនិងតំបន់



# បំណែងចែកប្រភេទនៃចំនួនពលករបរទេស




**(1) អ្នកស្នាក់នៅតាមអត្តសញ្ញាណ - ប្រហែល 532,000 នាក់**
(ជាទូទៅគឺ "អ្នកតាំងលំនៅអចិន្ត្រៃយ៍"(ពិសេសអ្នកជាប់សាច់ឈាមជប៉ុន) "អ្នកស្នាក់នៅអចិន្ត្រៃយ៍" "សហព័ទ្ធរបស់ជនជាតិជប៉ុន។ល។") ដោយសារលក្ខណ:សម្បត្តិស្នាក់នៅទាំងនេះគ្មានការកំណត់ព្រំដែននៃសកម្មភាពពេលស្នាក់នៅ គេអាចធ្វើសកម្មភាពដោយទទួលប្រាក់កំរៃនៅវិស័យផ្សេងៗបាន។

**(2) អ្នកស្នាក់នៅដើម្បីធ្វើការ – ប្រហែល 329,000 នាក់**
(ជាទូទៅគឺ"ក្នុងវិស័យឯកទេសនិងបច្ចេកទេស")
・ ចំពោះលក្ខណ:សម្បត្តិស្នាក់នៅខ្លះ គេកំណត់លក្ខខណ្ឌអនុញ្ញាតអោយចូលប្រទេសជប៉ុនដោយពិចារណាលើ "ផលប៉ះពាល់លើឧស្សាហកម្មនិងជីវភាពពលរដ្ឋនិងបញ្ហាផ្សេងទៀត"។

**(3) សកម្មភាពកំណត់ – ប្រហែល 41,000 នាក់**
(គិលានុប្បដ្ឋាក បេក្ខជនអ្នកថែទាំសុខុមាលភាពបរទេសផ្អែកលើEPA ធ្វើការពេលវិស្សមកាល អ្នកធ្វើការសំណង់ជាជនបរទេស អ្នកធ្វើការផលិតនាវាជាជនបរទេស។ល។)
・ ចំពោះអ្នកស្នាក់នៅជប៉ុនដោយលក្ខណ:សម្បត្តិស្នាក់នៅ"**សកម្មភាពកំណត់**" គឺគេកំណត់ការអនុញ្ញាតអោយទទួលប្រាក់កំរៃឬអត់ទៅតាមខ្លឹមសារនៃការអនុញ្ញាតនិមួយៗ។

**(4) កម្មសិក្សាការីជំនាញ – ប្រហែល 384,000 នាក់**
គោលបំណងគឺដើម្បីសហប្រតិបត្តិការអន្តរជាតិទៅដល់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយ:ការផ្ទេរជំនាញ។
យោងតាមការអនុវត្តន៍នៃវិសោធនកម្មច្បាប់អន្តោប្រវេសន៍ចាប់ពីថ្ងៃទី1ខែកក្កដាឆ្នាំ 2010 កម្មសិក្សាការីជំនាញទទួលបានលក្ខណ:សម្បត្តិស្នាក់នៅ"កម្មសិក្សាជំនាញ"ដែលមានឋាន:ជានិយោជិកចាប់តាំងពីឆ្នាំទី1នៅពេលមកដល់ប្រទេសជប៉ុន (ចំពោះកម្មសិក្សាការីដែលប្តូរលក្ខណ:សម្បត្តិស្នាក់នៅក្រោយពីពេលនោះគឺដូចគ្នា។)។

**(5) សកម្មភាពក្រៅលក្ខណ:សម្បត្តិ** (ការងារក្រៅម៉ោងរបស់និស្សិតបរទេស។ល។) **– ប្រហែល 373,000 នាក់**
・ គេអនុញ្ញាតអោយធ្វើសកម្មភាពដែលអាចទទួលប្រាក់កំរៃក្នុងករណីសមស្រប នៅក្នុងកំរិតដែលមិនប៉ះពាល់ដល់លក្ខណ:សម្បត្តិស្នាក់នៅដើម (ក្នុងចន្លោះ28ម៉ោងក្នុង1សប្តាហ៍ជាដើម)។

ស្ថិតិផ្អែកលើសេចក្តីសរុបនៃ "ស្ថានភាពនិយោជន៍ជនបរទេស" របស់ MHLW (ស្ថិតិចុងខែតុលា នៃឆ្នាំនិមួយៗ)

# ការទទួលយកពលករបរទេស

## ផ្នត់គំនិតមូលដ្ឋានបច្ចុប្បន្ន

**ជនបរទេសក្នុងវិស័យដែលមានឯកទេសនិងបច្ចេកទេស**

### ទទួលយកយ៉ាងសកម្ម

- ជំរុញការទទួលយកពលករបរទេសក្នុងវិស័យដែលមានឯកទេសនិងបច្ចេកទេស ដោយផ្អែកលើចក្ខុវិស័យជំរុញសកម្មភាពរបស់សង្គមសេដ្ឋកិច្ចនិងលើកកំពស់សកលភាវូបណីយកម្មមួយកំរិតទៀតរបស់ប្រទេសជប៉ុន
  (ផែនការមូលដ្ឋានដែលជាវិធានការការងារលើកទី៩ (សម្រេចដោយគណៈរដ្ឋមន្ត្រី))
- ជាការចាំបាច់ក្នុងការទទួលយកដោយសកម្មនូវជនបរទេសក្នុងវិស័យដែលមានឯកទេសនិងបច្ចេកទេសដែលចូលរួមចំណែកជំរុញសកម្មភាពរបស់សង្គមសេដ្ឋកិច្ចប្រទេសជប៉ុន ហើយត្រូវចាត់វិធានការអោយការទទួលយកមានភាពរលូន តាមរយៈការធ្វើអោយមានភាពជាក់លាក់នៃនីតិវិធីក្នុងការអនុវត្តន៍ការសម្រេចផ្តល់លក្ខណៈសម្បត្តិស្នាក់នៅ និងការសម្រាលបន្ទុកនីតិវិធីស្នើសុំ។ (ផែនការមូលដ្ឋានសំរាប់គ្រប់គ្រងអន្តោប្រវេសន៍ (ក្រសួងយុត្តិធម៌))

**ជនបរទេសក្នុងវិស័យផ្សេងទៀត**

### ត្រូវការពិចារណាលើចំណុចផ្សេងៗ

- ដោយសារមានការប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមសេដ្ឋកិច្ច និងជីវភាពពលរដ្ឋជប៉ុនជាដើម គេត្រូវឆ្លើយតបដោយប្រុងប្រយ័ត្នគ្រប់គ្រាន់ តាមរយៈការស្វែងរកការយល់ស្របរបស់ពលរដ្ឋផង
  (ផែនការមូលដ្ឋានដែលជាវិធានការការងារលើកទី៩ (សម្រេចដោយគណៈរដ្ឋមន្ត្រី))
- យ៉ាងណាមិញ ចំពោះការទទួលយកជនបរទេសនៅអនាគត គេត្រូវក្តាប់ស្ថានការណ៍នៃច្បាប់របស់ប្រទេសនិមួយៗ បូករួមជាមួយនឹងការស្តាប់សំលេងរបស់ពលរដ្ឋដោយយកចិត្តទុកដាក់ ត្រូវធ្វើការពិចារណាអោយទូលំទូលាយនៅក្នុងរដ្ឋាភិបាលទាំងមូល ដោយផ្អែកលើស្ថានភាពនៃការអនុវត្តន៍លក្ខណៈសម្បត្តិស្នាក់នៅ”ពលករជំនាញ” ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងដោះស្រាយបញ្ហាកង្វះកំលាំងពលកម្ម។
  (ផែនការមូលដ្ឋានសំរាប់គ្រប់គ្រងអន្តោប្រវេសន៍ (ក្រសួងយុត្តិធម៌))

# ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (I) អំពីលក្ខណៈសម្បត្តិស្នាក់នៅ



- **ពលករជំនាញកម្រិត១**៖ជាលក្ខណៈសម្បត្តិស្នាក់នៅសំរាប់ជនបរទេស ដែលធ្វើការងារតម្រូវឲ្យមានជំនាញដែលត្រូវការចំណេះដឹងឬបទពិសោធន៍ក្នុងកំរិតគួរសមសម្រាប់វិស័យឧស្សាហកម្មកំណត់ណាមួយ
- **ពលករជំនាញកម្រិត២**៖ជាលក្ខណៈសម្បត្តិស្នាក់នៅសំរាប់ជនបរទេស ដែលធ្វើការងារតម្រូវឲ្យមានជំនាញក្នុងកំរិតខ្ពស់សម្រាប់វិស័យឧស្សាហកម្មកំណត់ណាមួយ

វិស័យឧស្សាហកម្មកំណត់ (14 វិស័យ)៖ ការថែទាំមនុស្ស ការសម្អាតអគារ ឧស្សាហកម្មផលិតគ្រឿងបន្លាស់និងគ្រឿងឧបករណ៍ ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិចនិងព័ត៌មាន ការងារសំណង់ ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា ការជួសជុលរថយន្ត ការងារអាកាសចរណ៍ ការស្នាក់នៅ កសិកម្ម នេសាទនិងវារីវប្បកម្ម ការផលិតអាហារនិងភេសជ្ជៈ ឧស្សាហកម្មភោជនីយដ្ឋាន

(ចំពោះ ពលករជំនាញកម្រិត២គឺទទួលយកបានតែ2 វិស័យដែលមានគូសបន្ទាត់ពីក្រោម)

## ចំណុចសំខាន់នៃពលករជំនាញកម្រិត១

- រយៈពេលស្នាក់នៅ៖ ពន្យាររយៈពេលស្នាក់នៅរៀងរាល់ 4ខែម្តង 6ខែម្តង ឬ 12ខែម្តងសរុបរយៈពេលអតិប្បរមាត្រឹម5ឆ្នាំ
- កំរិតសមត្ថភាពជំនាញ ៖ពិនិត្យសម្រេចតាមរយៈការប្រឡង(ជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ ត្រូវបានលើកលែងមិនបាច់ប្រឡង)
- កំរិតសមត្ថភាពភាសាជប៉ុន៖ ពិនិត្យសម្រេចតាមរយៈការប្រឡងសមត្ថភាពភាសាជប៉ុនប្រើប្រាស់ចាំបាច់នៅក្នុងជីវភាពប្រចាំថ្ងៃនិងការងារ (ជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ ត្រូវបានលើកលែងមិនបាច់ប្រឡង)
- ការនាំគ្រួសារមកជាមួយ៖ ជាគោលការណ៍មិនអនុញ្ញាត
- ជាគោលដៅនៃការផ្តល់ការគាំទ្រដោយស្ថាប័នទទួលយកពលករ ឬស្ថាប័នគាំទ្រចុះបញ្ជី

## ចំណុចសំខាន់នៃពលករជំនាញកម្រិត២

- រយៈពេលស្នាក់នៅ៖ ពន្យាររយៈពេលស្នាក់នៅរៀងរាល់ 6ខែម្តង ឬ1 ឆ្នាំម្តង ឬ3ឆ្នាំម្តង
- កំរិតសមត្ថភាពជំនាញ៖ ពិនិត្យសម្រេចតាមរយៈការប្រឡង
- កំរិតសមត្ថភាពភាសាជប៉ុន៖ មិនចាំបាច់ត្រួតពិនិត្យដោយការប្រឡងជាដើមឡើយ
- ការនាំគ្រួសារមកជាមួយ៖ អាចបានក្នុងករណីបំពេញលក្ខខណ្ឌ (សហព័ទ្ធ កូន)
- មិនមែនជាគោលដៅនៃការផ្តល់ការគាំទ្រដោយស្ថាប័នទទួលយកពលករ ឬស្ថាប័នគាំទ្រចុះបញ្ជី

[កំរិតសមត្ថភាពជំនាញនៃលក្ខណៈសម្បត្តិស្នាក់នៅដែលគេអនុញ្ញាតអោយធ្វើការ]



# អំពីគោលការណ៍នៃវិស័យនិមួយៗ (14វិស័យ)

| | វិស័យ | ស្ថានភាពកង្វះពលកម្ម | ស្តង់ដារ HR | | ចំណុចសំខាន់ផ្សេងទៀត | | |
|---|---|---|---|---|---|---|---|
| | | ចំនួនជាន់ស្មានទទួល (តំលៃធំបំផុត5ឆ្នាំ)(*) | ការប្រឡងជំនាញបច្ចេកទេស | ការប្រឡងភាសាជប៉ុន | ការងារត្រូវធ្វើ | ទម្រង់នៃការជួល | លក្ខខណ្ឌដែលស្ថាប័នទទួលត្រូវបំពេញ |
| ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព | ការថែទាំមនុស្ស | 60,000 នាក់ | ប្រឡងវាយតំលៃជំនាញថែទាំ | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិត N4 ឡើង (បន្ថែមពីលើនេះ) មានការប្រឡងវាយតំលៃភាសាជប៉ុនសំរាប់ការថែទាំមនុស្ស | -ការថែទាំរាងកាយ។ល។(ការជ្រោមជ្រែងដល់ការងូតទឹក ការបរិភោគ ការបន្ទោបង់ ទៅតាមស្ថានភាពនៃរាងកាយនិងសតិរបស់អ្នកប្រើប្រាស់ជាដើម) និងការងារគាំពារទាក់ទងនឹងសកម្មភាពនេះ (ការអនុវត្តន៍កម្មវិធីកំសាន្ត ការជួយដល់ការហ្វឹកហាត់មុខងារ។ល។) (សំគាល់) ប្រភេទសេវាកម្មទៅដល់ផ្ទះមិនមែនជាកម្មវត្ថុឡើយ (1 ផ្នែកប្រឡង) | ដោយផ្ទាល់ | •ត្រូវចូលរួមក្នុងគណ:កម្មាធិការដែលរៀបចំឡើងដោយ MHLW ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>•ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MHLW<br>•កំណត់ចំនួនទទួលសំរាប់ទីតាំងអាជីវកម្មនិមួយៗ |
| | ការសម្អាតអគារ | 37,000 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យសម្អាតអគារ | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | - ការងារសម្អាតផ្នែកខាងក្នុងអគារ (1 ផ្នែកប្រឡង) | ដោយផ្ទាល់ | •ត្រូវចូលរួមក្នុងគណ:កម្មាធិការដែលរៀបចំឡើងដោយ MHLW ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>•ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MHLW<br>•ត្រូវមានចុះបញ្ជីក្នុង"សមាគមសម្អាតអគារ" ឬ "សមាគមគ្រប់គ្រងទូទៅលើអនាម័យបរិស្ថានក្នុងអគារ" |
| ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម | ឧស្សាហកម្មផលិតគ្រឿងបន្លាស់ និងគ្រឿងឧបករណ៍ | 21,500 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យផលិតកម្ម | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការចាក់ពុម្ពលោហ: • ការងារបន្ទះដែករោងចក្រ<br>• ការត្រួតពិនិត្យម៉ាស៊ីន<br>• ការដំដែក • ការក្រូមេ • ការថែទាំម៉ាស៊ីន<br>• ការសិតដែក • អាលួតកម្មអាលុយមីញ៉ូម • ការលាបថ្នាំ<br>• ការច្នៃដោយម៉ាស៊ីន • ការផ្សារ<br>• ការច្នៃដោយគាបលោហ:ធាតុ • ការសំអាងចុងក្រោយ<br>(13 ផ្នែកប្រឡង) | ដោយផ្ទាល់ | •ត្រូវចូលរួមក្នុងគណ:កម្មាធិការដែលរៀបចំឡើងដោយ METI ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>•ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ METI |
| | ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម | 5,250 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យផលិតកម្ម | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡង Japanese Language Proficiency Test កំរិតN4 ឡើង | • ការចាក់ពុម្ពលោហ: • ការងារបន្ទះដែករោងចក្រ • ការផ្គុំឧបករណ៍អេឡិចត្រូនិច<br>• ការដំដែក • ការក្រូមេ • ការផ្គុំឧបករណ៍អគ្គិសនី<br>• ការសិតដែក • ការសំអាងចុងក្រោយ • ការផលិតបន្ទះសៀគ្វីពុម្ព<br>• ការច្នៃដោយម៉ាស៊ីន • ការត្រួតពិនិត្យម៉ាស៊ីន • ការចាក់ពុម្ពប្លាស្ទិក<br>• ការលាបថ្នាំ • ការថែទាំម៉ាស៊ីន • ការច្នៃដោយគាបលោហ:ធាតុ<br>• ការងារជាងដែក • ការវេចខ្ចប់លក្ខណ:ឧស្សាហកម្ម • ការងារផ្សារ<br>(18 ផ្នែកប្រឡង) | ដោយផ្ទាល់ | •ត្រូវចូលរួមក្នុងគណ:កម្មាធិការដែលរៀបចំឡើងដោយ METI ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>•ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ METI |
| | ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិច និងព័ត៌មាន | 4,700 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យផលិតកម្ម | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡង Japanese Language Proficiency Test កំរិតN4 ឡើង | • ការច្នៃដោយម៉ាស៊ីន • ការថែទាំម៉ាស៊ីន • ការលាបថ្នាំ<br>• ការច្នៃដោយគាបលោហ:ធាតុ • ការផ្គុំឧបករណ៍អេឡិចត្រូនិច • ការងារផ្សារ<br>• ការងារបន្ទះដែករោងចក្រ • ការផ្គុំឧបករណ៍អគ្គិសនី<br>• ការវេចខ្ចប់លក្ខណ:ឧស្សាហកម្ម<br>• ការក្រូមេ • ការផលិតបន្ទះសៀគ្វីពុម្ព<br>• ការសំអាងចុងក្រោយ • ការចាក់ពុម្ពប្លាស្ទិក<br>(13 ផ្នែកប្រឡង) | ដោយផ្ទាល់ | •ត្រូវចូលរួមក្នុងគណ:កម្មាធិការដែលរៀបចំឡើងដោយ METI ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>•ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ METI |

# អំពីគោលការណ៍នៃវិស័យនិមួយៗ (14វិស័យ)

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ | ការងារសំណង់ | 40,000 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ក្នុងវិស័យសំណង់ | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការងារពុម្ព • ការងារដី<br>• ការងារសំអាងខាងក្នុង/ ការងារតុបតែង<br>• ការងារបូក • ការងារប្រក់ដំបូល • ការងារបូមបេតុង<br>• ការងារគមនាគមន៍អគ្គិសនី • ការងាររួងក្រោមដី<br>• ការងារតម្លើងដែកបារ • ការងារម៉ាស៊ីនសំណង់<br>• ការងារតំណដែកបារ • ការងាររន្ទា<br>• ការងារសាងសង់អគារអំពីឈើ • ការងារតទុយោ<br>• ការងារដែកបន្ទះសំរាប់សំណង់ • ការគ្រប់គ្រងក្តៅត្រជាក់<br>• ការងារបាញ់អ៊ីសូឡង់កំដៅ Urethane<br>• ការងារសំណង់ក្នុងសមុទ្រ<br>(18 ផ្នែកប្រឡង) | ដោយផ្ទាល់ | • ត្រូវតែចូលជាសមាជិកសមាគមសហគ្រាសសាងសង់ដែលទាក់ទងនឹងការទទួលយកជនបរទេស<br>• ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយMLIT<br>• ត្រូវមានលិខិតអនុញ្ញាតិអនុលោមតាមច្បាប់សហគ្រាសសាងសង់<br>• ត្រូវធ្វើកិច្ចសន្យាបើកប្រាក់កំរៃក្នុងកំរិតស្មើឬលើសជនជាតិជប៉ុនអោយបានទៀងទាត់ ហើយតំលើងប្រាក់កំរៃទៅតាមកំរិតស្ទាត់នៃជំនាញ<br>• ចំពោះចំណុចសំខាន់ទាក់ទងនឹងកិច្ចសន្យាការងារ ត្រូវធ្វើការពន្យល់ដោយមានឯកសារជាភាសាកំណើត<br>• កំណត់ចំនួនទទួលយកសំរាប់សហគ្រាសសាងសង់ដែលទទួលយកនិមួយៗ<br>• ទទួលបានការទទួលស្គាល់ពី MLIT "ផែនការទទួលយកពលករជំនាញសំណង់" ដែលមានបំពេញនូវប្រាក់កំរៃ។ល។<br>• ទទួលបានការបញ្ជាក់ថាបានអនុវត្តន៍"ផែនការទទួលយកពលករជំនាញសំណង់"ដែលទទួលស្គាល់ដោយ MLIT ដោយត្រឹមត្រូវ<br>• ត្រូវចុះបញ្ជីឈ្មោះពលករជំនាញជនបរទេសនៅក្នុងប្រព័ន្ធជំរុញអាជីពសំណង់ |
| | ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា | 13,000 នាក់ | ការប្រឡងសំរាប់ពលករជំនាញកម្រិត១ក្នុងវិស័យផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការងារផ្សា • ការងារសំអាងចុងក្រោយ<br>• ការងារលាប • ការច្នៃដោយម៉ាស៊ីន<br>• ការងារជាងដែក • ការផ្គុំឧបករណ៍អគ្គិសនី<br>(6 ផ្នែកប្រឡង) | ដោយផ្ទាល់ | • ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MLIT ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>• ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយMLIT<br>• នៅពេលដួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ |
| | ការជួសជុលរថយន្ត | 7,000 នាក់ | ប្រឡងវាយតំលៃសំរាប់ពលករជំនាញកម្រិត១ក្នុងវិស័យជួសជុលនិងថែទាំរថយន្ត | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការថែទាំត្រួតពិនិត្យរថយន្តប្រចាំថ្ងៃ ការថែទាំត្រួតពិនិត្យទៀងទាត់តាមពេលកំណត់ ការថែទាំដោះគ្រឿងបង្គុំ<br>(1 ផ្នែកប្រឡង) | ដោយផ្ទាល់ | • ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MLIT ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>• ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយMLIT<br>• នៅពេលដួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ<br>• ត្រូវតែជាទីតាំងអាជីវកម្មដែលបានទទួលវិញ្ញាបនកម្មយោងតាមច្បាប់ស្តីអំពីយានយន្តដឹកជញ្ជូនតាមផ្លូវថ្នល់ |
| | ការងារអាកាសចរណ៍ | 2,200 នាក់ | ការប្រឡងវាយតំលៃសំរាប់ពលករជំនាញ(វិស័យអាកាសចរណ៍:ការងារលើដីនៅព្រលានយន្តហោះ ការងារថែទាំយន្តហោះ) | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការងារលើដីនៅព្រលានយន្តហោះ (ការងារជំនួយការបើកបរលើដី ការងារដោះស្រាយអីវ៉ាន់អ្នកដំណើរ និងទំនិញ។ល។)<br>• ការងារថែទាំយន្តហោះ (ការងារថែទាំតួយន្តហោះ និងគ្រឿងគ្រឿងបរិក្ខារ។ល។)<br>(2 ផ្នែកប្រឡង) | ដោយផ្ទាល់ | • ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MLIT ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>• ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយMLIT<br>• នៅពេលដួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ<br>• ជាសហគ្រាសដែលបានទទួលបានការអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងទីលានស្របតាមច្បាប់ស្តីអំពីការគ្រប់គ្រងព្រលានយន្តហោះ ឬជាសហគ្រាសមានអាជ្ញាប័ណ្ណទាក់ទងនឹងការងារថែទាំយន្តហោះជាដើម ស្របតាមច្បាប់អាកាសចរណ៍ |
| | ការស្នាក់នៅ | 22,000 នាក់ | ការប្រឡងវាស់សមត្ថភាពវិស័យរៀបចំបន្ទប់ស្នាក់នៅ | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | • ការផ្តល់សេវាកម្មស្នាក់នៅ ដូចជាការងារទទួលអតិថិជន ធ្វើផែនការ ឬទំនាក់ទំនងសាធារណៈ បដិសណ្ឋារកិច្ច សេវាកម្មភោជនីយដ្ឋាន<br>(1 ផ្នែកប្រឡង) | ដោយផ្ទាល់ | • ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MLIT ហើយត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់<br>• ត្រូវផ្តល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MLIT<br>• នៅពេលដួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ<br>• ជាអ្នកដែលទទួលបានការអនុញ្ញាតសំរាប់"ប្រតិបត្តិការផ្ទះសំណាក់ឬសណ្ឋាគារ"<br>• មិនមែនជាទីតាំងដែលចាត់ចូលក្នុងប្រភេទទីតាំងពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទ<br>• មិនអោយទទួលភ្ញៀវពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទ |

# អំពីគោលការណ៍នៃវិស័យនិមួយៗ (14វិស័យ)

| | | | | | | | |
|---|---|---|---|---|---|---|---|
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កសិកម្ម | 36,500 នាក់ | ការប្រឡងវាស់ជំនាញកសិកម្ម | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | ・ កសិកម្មផ្នែកដាំដុះទូទៅ (ការគ្រប់គ្រងការដាំដុះ ការប្រមូល ប្រគល់ទំនិញ និងបែងចែកកសិផល។ល។)<br>・ កសិកម្មផ្នែកចិញ្ចឹមសត្វទូទៅ (ការគ្រប់គ្រងការចិញ្ចឹម ការប្រមូល ប្រគល់ទំនិញនិងបែងចែកទំនិញ។ល។)<br>(2 ផ្នែកប្រឡង) | ដោយផ្ទាល់ បញ្ជូន | ・ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MAFF ហើយត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់<br>・ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MAFF<br>・នៅពេលជួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ<br>・ជាអាជីវកម្មកសិកម្មដែលធ្លាប់មានបទពិសោធន៍ជួលពលករក្នុងកំឡុងពេលកំណត់មួយ |
| | នេសាទ និងវារីវប្បកម្ម | 9,000 នាក់ | ការប្រឡងវាស់ជំនាញនេសាទ(នេសាទឬវារីវប្បកម្ម) | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | ・ នេសាទ (ការផលិតនិងជួសជុលឧបករណ៍នេសាទ ការស្វែងរកជលផល ការបញ្ជាឧបករណ៍និងម៉ាស៊ីននេសាទ ការប្រមូលជលផល ចំណាត់ការនិងការរក្សាទុកនៃជលផល ការរក្សាសុវត្ថិភាពនិងអនាម័យ។ល។)<br>・ ឧស្សាហកម្មវារីវប្បកម្ម (ការផលិត ជួសជុល គ្រប់គ្រងនៃបរិក្ខារវារីវប្បកម្ម ការគ្រប់គ្រង ប្រមូលផល (ចាប់) ចំណាត់ការ ការរក្សាសុវត្ថិភាពនិងអនាម័យនៃផលិតផលវារីវប្បកម្ម។ល។)<br>(2 ផ្នែកប្រឡង) | ដោយផ្ទាល់ បញ្ជូន | ・ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MAFF ហើយត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់<br>・ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MAFF<br>・ត្រូវចាត់វិធានការដែលគណៈកម្មាធិការដែលរៀបចំឡើងដោយ MAFF បានប្រជុំសម្រេចដាក់ចេញ<br>・នៅពេលជួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រត្រូវជ្រើសរើសស្ថាប័នគាំទ្រដែលបំពេញលក្ខខណ្ឌខាងលើ |
| | ការផលិតអាហារ និងភេសជ្ជៈ | 34,000 នាក់ | ការប្រឡងវាស់ជំនាញសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យផលិតអាហារ និងភេសជ្ជៈ | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | ・ ការងារផលិតគ្រឿងបរិភោគទូទៅ និងភេសជ្ជៈ(ការផលិត ការកែច្នៃ ការរក្សាសុវត្ថិភាពនិងអនាម័យនៃគ្រឿងបរិភោគ និងភេសជ្ជៈ (ក្រៅពីគ្រឿងស្រវឹង))<br>(1 ផ្នែកប្រឡង) | ដោយផ្ទាល់ | ・ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MAFF ហើយត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់<br>・ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MAFF |
| | ឧស្សាហកម្មភោជនីយដ្ឋាន | 53, 000 នាក់ | ការប្រឡងវាស់ជំនាញសំរាប់ពលករជំនាញកម្រិត១ ក្នុងវិស័យភោជនីយដ្ឋាន | ប្រឡងJapan Foundation Test for Basic Japanese ឬប្រឡងJapanese Language Proficiency Test កំរិតN4 ឡើង | ・ ការងារភោជនីយដ្ឋានទូទៅ (ការធ្វើម្ហូបឬភេសជ្ជៈ ការទទួលភ្ញៀវ ការគ្រប់គ្រងហាង)<br>(1 ផ្នែកប្រឡង) | ដោយផ្ទាល់ | ・ត្រូវចូលរួមក្នុងគណៈកម្មាធិការដែលរៀបចំឡើងដោយ MAFF ហើយត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់<br>・ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការចាំបាច់ដល់ការអង្កេតឬការណែនាំដែលធ្វើឡើងដោយ MAFF<br>・មិនអោយទៅធ្វើការនៅទីតាំងអាជីវកម្មពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទ<br>・មិនអោយទទួលភ្ញៀវពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទ |

សំគាល់៖ ចំនួនប៉ាន់ស្មាននឹងទទួលយកសរុបក្នុង14វិស័យ (ចំនួនអតិបរមាសំរាប់5ឆ្នាំ)៖ 345,150

# ការប្រៀបធៀបរវាងប្រព័ន្ធកម្មសិក្សាជំនាញ និងប្រព័ន្ធពលករជំនាញ (ទិដ្ឋភាពទូទៅ)

| | កម្មសិក្សាជំនាញ (ប្រភេទគ្រប់គ្រងដោយសមាគម) | ពលករជំនាញកម្រិត១ |
|---|---|---|
| ច្បាប់ពាក់ព័ន្ធ | ច្បាប់ពាក់ព័ន្ធនឹងការអនុវត្តន៍ដោយត្រឹមត្រូវនៃកម្មសិក្សាជំនាញរបស់ជនបរទេស និងច្បាប់ស្ដីអំពីការការពារកម្មសិក្សាការីជំនាញ និងច្បាប់គ្រប់គ្រងអន្តោប្រវេសន៍និងទទួលស្គាល់ជនភៀសខ្លួន | ច្បាប់គ្រប់គ្រងអន្តោប្រវេសន៍និងទទួលស្គាល់ជនភៀសខ្លួន |
| លក្ខណ:សម្បត្តិស្នាក់នៅ | លក្ខណ:សម្បត្តិស្នាក់នៅ៖ “កម្មសិក្សាជំនាញ” | លក្ខណ:សម្បត្តិស្នាក់នៅ៖ “ពលករជំនាញ” |
| រយ:ពេលស្នាក់នៅ | កម្មសិក្សាជំនាញកម្រិត១ ៖ រយ:ពេលត្រឹម1ឆ្នាំ កម្មសិក្សាជំនាញកម្រិត២ ៖ រយ:ពេលត្រឹម2ឆ្នាំ កម្មសិក្សាជំនាញកម្រិត៣ ៖ រយ:ពេលត្រឹម2ឆ្នាំ (សរុបមកយូរបំផុតត្រឹម 5ឆ្នាំ) | សរុបទាំងអស់ត្រឹម 5ឆ្នាំ |
| កំរិតសមត្ថភាពជំនាញរបស់ជនបរទេស | គ្មាន | ត្រូវការចំណេះដឹងឬបទពិសោធន៍ក្នុងកំរិតគួរសម |
| ការប្រឡងដើម្បីចូលជប៉ុន | គ្មាន<br>(មានតែចំពោះប្រភេទការងារថែទាំមនុស្សប៉ុណ្ណោះដែលមានលក្ខខណ្ឌតម្រូវអោយមានសមត្ថភាពភាសាជប៉ុនកំរិត N4) | ត្រួតពិនិត្យកំរិតសមត្ថភាពជំនាញនិងកំរិតសមត្ថភាពភាសាជប៉ុនដោយការប្រឡង។ល។<br>(ត្រូវបានលើកលែងចំពោះជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ដោយត្រឹមត្រូវ) |
| ស្ថាប័នបញ្ជូន | ស្ថាប័នដែលរដ្ឋាភិបាលបរទេសណែនាំឬទទួលស្គាល់ | គ្មាន |
| សមាគមគ្រប់គ្រង | មាន<br>(សមាគមអាជីវកម្មមិនរកប្រាក់ចំណេញជាដើមធ្វើសវនកម្មលើការអនុវត្តន៍កម្មសិក្សានិងការងារគ្រប់គ្រង។ល។ជាប្រព័ន្ធអនុញ្ញាតដោយរដ្ឋមន្ត្រីមានសមត្ថកិច្ច) | គ្មាន |
| ស្ថាប័នគាំទ្រ | គ្មាន | មាន<br>(បុគ្គលឬស្ថាប័នដែលបានទទួលការជួលពីស្ថាប័នទទួល ធ្វើការស្វែងរកកន្លែងស្នាក់នៅនិងការគាំទ្រផ្សេងទៀតដល់ពលករជំនាញបរទេស។ ជាប្រព័ន្ធចុះបញ្ជីនៅភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន) |
| ភាពត្រូវគ្នារវាងជនបរទេសនិងស្ថាប័នទទួល | ជាទូទៅធ្វើឡើងតាមរយ:សមាគមគ្រប់គ្រងនិងស្ថាប័នបញ្ជូន | ស្ថាប័នទទួលអាចធ្វើសកម្មភាពជ្រើសរើសបុគ្គលិកនៅបរទេសដោយផ្ទាល់ឬតាមរយ:ភ្នាក់ងារណែនាំក្នុងនិងក្រៅប្រទេស |
| ចំនួនកំណត់សំរាប់ស្ថាប័នទទួល | មានការកំណត់ចំនួនទៅតាមចំនួនបុគ្គលិកពេញម៉ោង | គ្មានចំនួនកំណត់ (លើកលែងតែវិស័យថែទាំមនុស្ស និងវិស័យសំណង់) |
| ខ្លឹមសារនៃសកម្មភាព | សកម្មភាពផ្អែកលើផែនការកម្មសិក្សាជំនាញកម្រិត១ ដោយទទួលការបង្រៀន និងធ្វើការងារទាក់ទងនឹងជំនាញ<br>សកម្មភាពដែលត្រូវការជំនាញជាដើម ដោយផ្អែកលើផែនការកម្មសិក្សាជំនាញ(កម្រិត២ កម្រិត៣)<br>(វិស័យគ្មានឯកទេសនិងបច្ចេកទេស) | ធ្វើការងារតម្រូវឲ្យមានជំនាញដែលត្រូវការចំណេះដឹងឬបទពិសោធន៍ក្នុងកំរិតគួរសម<br>(វិស័យមានឯកទេសនិងបច្ចេកទេស) |
| ការប្តូរស្ថាប័នធ្វើការ ការប្តូរប្រភេទការងារ | ជាទូទៅមិនបានឡើយ។ ប៉ុន្តែក្នុងករណីចាំបាច់ដូចជាការក្ស័យធនរបស់អ្នកអនុវត្តកម្មសិក្សា និងពេលបន្តពីកម្រិត២ទៅកម្រិត៣ គឺអាចប្តូរស្ថាប័នធ្វើការបាន | អាចប្តូរការងារនៅក្នុងចន្លោះផ្នែកការងារមួយ ឬក្នុងករណីដែលគេអាចពិនិត្យមើលពីភាពដូចគ្នានៃកំរិតសមត្ថភាពជំនាញតាមរយ:ការប្រឡងជាដើម នោះគេអាចប្តូរការងាររវាងផ្នែកនៃការងារ |

# ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (2) អំពីស្ថាប័នទទួលនិងស្ថាប័នគាំទ្រចុះបញ្ជី

## អំពីស្ថាប័នទទួល

**1 　ស្តង់ដារដែលស្ថាប័នទទួលអាចទទួលយកជនបរទេសបាន**

(1) កិច្ចសន្យាការងារដែលបានចុះជាមួយជនបរទេសគឺសមស្រប (ឧទាហរណ៍ ៖ ប្រាក់កំរៃមានចំនួនស្មើឬលើសជនជាតិជប៉ុន)

(2) ស្ថាប័នសាមីមានលក្ខណៈសមស្រប (ឧទាហរណ៍ ៖ គ្មានការល្មើសច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារក្នុងអំឡុងពេល5ឆ្នាំចុងក្រោយ)

(3) មានប្រព័ន្ធគាំទ្រជនបរទេស (ឧទាហរណ៍ ៖ អាចគាំទ្រដោយភាសាដែលជនបរទេសអាចយល់បាន)

(4) ផែនការគាំទ្រជនបរទេសមានលក្ខណៈសមស្រប (ឧទាហរណ៍ ៖ រួមបញ្ចូលនូវការណែនាំអំពីរបៀបរបបរស់នៅជាដើមផង)

**2 　កាតព្វកិច្ចរបស់ស្ថាប័នទទួល**

(1) អនុវត្តកិច្ចសន្យាការងារដែលបានចុះជាមួយជនបរទេសដោយខ្ជាប់ខ្ជួន (ឧទាហរណ៍ ៖ បើកប្រាក់កំរៃអោយបានត្រឹមត្រូវ)

(2) អនុវត្តការគាំទ្រជនបរទេសអោយបានសមស្រប

→ ចំពោះការគាំទ្រ គេអាចជួលស្ថាប័នគាំទ្រចុះបញ្ជីក៏បាន។
បើគេជួលទាំងអស់ នោះគេអាចបានបំពេញលក្ខខណ្ឌ 1(3) រួចហើយ

(3) ការជូនដំណឹងគ្រប់ប្រភេទទៅភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

(សំគាល់) ក្នុងករណីខកខានមិនបានអនុវត្ត(1)ដល់(3) នោះមិនត្រឹមតែលែងអាចទទួលយកជនបរទេសប៉ុណ្ណោះទេ ថែមទាំងទទួលបទបញ្ជាណែនាំនិងកែលំអទៀតផង។

## អំពីស្ថាប័នគាំទ្រចុះបញ្ជី

**1 　ស្តង់ដារអាចទទួលការចុះបញ្ជី**

(1) ស្ថាប័នសាមីមានលក្ខណៈសមស្រប (ឧទាហរណ៍ ៖ គ្មានការល្មើសច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារក្នុងអំឡុងពេល5ឆ្នាំចុងក្រោយ)

(2) មានរចនាសម្ព័ន្ធគាំទ្រជនបរទេស (ឧទាហរណ៍ ៖ អាចគាំទ្រដោយភាសាដែលជនបរទេសអាចយល់បាន)

**2 　កាតព្វកិច្ចរបស់ស្ថាប័នគាំទ្រចុះបញ្ជី**

(1) អនុវត្តការគាំទ្រជនបរទេសអោយបានសមស្រប

(2) ជូនដំណឹងគ្រប់ប្រភេទទៅភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន

(សំគាល់) ក្នុងករណីខកខានមិនបានអនុវត្ត(1) និង (2) អាចត្រូវបានលុបចេញពីបញ្ជី។



# ទិដ្ឋភាពទូទៅនៃប្រព័ន្ធ (3) លំដាប់លំដោយរហូតដល់ចាប់ផ្តើមការងារ



## ពលរដ្ឋបរទេសដែលមកប្រទេសជប៉ុនពីបរទេស

| ជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ ដោយត្រឹមត្រូវ | ជនបរទេសដែលគ្រោងចូលប្រទេសជប៉ុនថ្មី |
| --- | --- |
| ត្រូវបានលើកលែងការប្រឡង (ជំនាញបច្ចេកទេស និងភាសាជប៉ុន) | បានជាប់ការប្រឡងនៅបរទេស (ជំនាញបច្ចេកទេស និងភាសាជប៉ុន) |

ដាក់ពាក្យសុំការងារឆ្លើយតបនឹងការជ្រើសរើសដោយផ្ទាល់/រកការណែនាំពីក្រុមហ៊ុនណែនាំការងារឯកជន

< ការប្រឡងជំនាញបច្ចេកទេស>

- ជាការប្រឡងតាមផ្នែកការងារនៃវិស័យឧស្សាហកម្មកំណត់

<ការប្រឡងភាសាជប៉ុន>

- ប្រឡង Japan Foundation Fundamental Japanese Test (Japan Foundation)
  ឬ
- ប្រឡង Japanese Language Proficiency Test (កំរិត N4 ឡើង)
  (Japan Foundation, Japan Educational Exchanges and Services)
  ។ល។



## ជនបរទេសដែលស្នាក់នៅប្រទេសជប៉ុន (អ្នកស្នាក់នៅរយៈពេលមធ្យមឬវែង)

| ជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ ដោយត្រឹមត្រូវ | និស្សិតបរទេស។ល។ |
| --- | --- |
| ត្រូវបានលើកលែងការប្រឡង (ជំនាញបច្ចេកទេសនិងភាសាជប៉ុន) | បានជាប់ការប្រឡង (ជំនាញបច្ចេកទេសនិងភាសាជប៉ុន) |

ដាក់ពាក្យសុំការងារឆ្លើយតបនឹងការជ្រើសរើសដោយផ្ទាល់ ឬរកការណែនាំពីក្រុមហ៊ុនណែនាំការងារឯកជន ឬហាឡូវើក

[ចុះកិច្ចសន្យាការងារជាមួយស្ថាប័នទទួល]
ទទួលសេចក្តីណែនាំជាមុន និងការពិនិត្យសុខភាពដែលធ្វើឡើងដោយស្ថាប័នទទួល

**(ពលរដ្ឋបរទេសដែលមកពីបរទេស)**

ការស្នើសុំ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណ:សម្បត្តិស្នាក់នៅ

* ស្នើសុំជំនួសដោយបុគ្គលិកស្ថាប័នទទួលជាដើម

## ការិយាល័យសេវាកម្មអន្តោប្រវេសន៍តាមតំបន់

ត្រួតពិនិត្យ

ផ្តល់ លិខិតបញ្ជាក់ការទទួលស្គាល់លក្ខណ:សម្បត្តិស្នាក់នៅ

ផ្ញើលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណ:សម្បត្តិស្នាក់នៅទៅស្ថាប័នទទួល



ស្នើសុំទិដ្ឋាការ

*យកលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណ:សម្បត្តិស្នាក់នៅដែលស្ថាប័នទទួលផ្ញើមក ទៅដាក់នៅស្ថានទូតឬស្ថានកុងស៊ុលនៅបរទេស

**ស្ថានទូតឬស្ថានកុងស៊ុលជប៉ុននៅបរទេស**

ត្រួតពិនិត្យ

ផ្តល់ទិដ្ឋាការ

ចូលប្រទេសជប៉ុន

ផ្តល់ប័ណ្ណស្នាក់នៅ
*មានករណីខ្លះផ្តល់នៅថ្ងៃក្រោយ

**(ជនបរទេសដែលស្នាក់នៅប្រទេសជប៉ុន)**

ការស្នើសុំប្តូរប្រភេទ លក្ខណ:សម្បត្តិស្នាក់នៅ

*ជាទូទៅសាមីខ្លួនជាអ្នកស្នើសុំ

ត្រួតពិនិត្យ

ផ្តល់ការអនុញ្ញាតប្តូរប្រភេទលក្ខណ:សម្បត្តិស្នាក់នៅ

ផ្តល់ប័ណ្ណស្នាក់នៅ

**លក្ខខណ្ឌនៃសាមីខ្លួនជនបរទេស**

- ○ មានអាយុចាប់ពី18ឆ្នាំឡើង
- ○ បានជាប់ការប្រឡងជំនាញបច្ចេកទេសនិងការប្រឡងភាសាជប៉ុន (ត្រូវបានលើកលែងចំពោះជនបរទេសដែលបានបញ្ចប់កម្មសិក្សាជំនាញកម្រិត២ដោយត្រឹមត្រូវ)
- ○ មិនបានស្នាក់នៅជប៉ុនសរុបលើសពី5ឆ្នាំក្រោមលក្ខណ:សម្បត្តិស្នាក់នៅពលករជំនាញកម្រិត១
- ○ មិនរងការទាមទារប្រាក់ធានា ឬមិនបានចុះកិច្ចសន្យាដែលកំណត់ប្រាក់សំណង
- ○ ក្នុងករណីដែលត្រូវចេញការចំណាយដោយខ្លួនឯង បានយល់ច្បាស់អំពីខ្លឹមសារនោះ

។ល។

[ក្រោយចូលប្រទេសជប៉ុន (ឬក្រោយប្តូរប្រភេទលក្ខណ:សម្បត្តិស្នាក់នៅ) ត្រូវអនុវត្តមិនអោយយឺតយ៉ាវ]

- ○ទទួលការណែនាំអំពីរបៀបរបបរស់នៅដែលធ្វើឡើងដោយស្ថាប័នទទួល
- ○ ចុះបញ្ជីស្នាក់នៅជាមួយរដ្ឋបាលមូលដ្ឋានដែលខ្លួនស្នាក់នៅ
- ○ បើកគណនីធនាគារសំរាប់បៀវត្ស
- ○ រកអោយបានកន្លែងស្នាក់នៅ

។ល។

## ចាប់ផ្តើមការងារនៅស្ថាប័នទទួល

# ទិដ្ឋភាពទូទៅនៃផែនការគាំទ្រ (1)



**ចំណុចសំខាន់**

○ស្ថាប័នទទួលត្រូវធ្វើផែនការទាក់ទងនឹងការអនុវត្តន៍ការគាំទ្រលើជីវភាពការងារ ជីវភាពប្រចាំថ្ងៃនិងជីវភាពសង្គមរបស់ពលករជំនាញកម្រិត១ជាជនបរទេស ធ្វើអោយសកម្មភាព"ពលករជំនាញកម្រិត១" មានលំនឹងនិងមានភាពរលូន (ផែនការគាំទ្រពលករជំនាញកម្រិត១ជាជនបរទេស។ខាងក្រោមហៅកាត់ថា"ផែនការគាំទ្រ"។) ហើយធ្វើការគាំទ្រតាមផែនការនោះ។

* ចំពោះពលករជំនាញកម្រិត២ គ្មានកាតព្វកិច្ចគាំទ្រឡើយ។

## ■ ការធ្វើផែនការគាំទ្រ

- ចំពោះស្ថាប័នទទួល នៅពេលធ្វើការស្នើសុំលក្ខណៈសម្បត្តិស្នាក់នៅផ្សេងៗ(*) ត្រូវធ្វើផែនការគាំទ្រ ហើយនៅពេលធ្វើការស្នើសុំត្រូវដាក់ជូនដោយភ្ជាប់ជាមួយឯកសារផ្សេងៗ។

*ការស្នើសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅទាក់ទងនឹងពលករជំនាញកម្រិត១ ការស្នើសុំការអនុញ្ញាតប្តូរលក្ខណៈសម្បត្តិស្នាក់នៅ។ល។

## ■ ចំណុចសំខាន់ៗត្រូវបំពេញក្នុងផែនការគាំទ្រ

- ខ្លឹមសារនិងវិធីអនុវត្តន៍នៃចំណុចទាំង10ដែលកំណត់ដោយប្រកាស (សូមមើលទំព័រ14) ដែលគេគិតថាចាំបាច់ក្នុងការគាំទ្រលើជីវភាពការងារ ជីវភាពប្រចាំថ្ងៃនិងជីវភាពសង្គម។ល។
- ឈ្មោះនិងមុខងាររបស់អ្នកទទួលខុសត្រូវក្នុងការគាំទ្រនិងអ្នកអនុវត្តន៍ការគាំទ្រជាដើម
- ក្នុងករណីជួលអ្នកដទៃអោយអនុវត្តន៍ការគាំទ្រ ត្រូវមានឈ្មោះនិងអាស័យដ្ឋានរបស់អ្នកនោះជាដើម
- ស្ថាប័នគាំទ្រចុះបញ្ជី(តែក្នុងករណីជួលស្ថាប័នគាំទ្រចុះបញ្ជីប៉ុណ្ណោះ)

## ■ ការជួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រ

- ស្ថាប័នទទួលអាចជួលអ្នកដទៃអោយអនុវត្តផែនការគាំទ្រទាំងស្រុងឬមួយផ្នែកបាន(ចុះកិច្ចសន្យាជួលអោយធ្វើការគាំទ្រ)។
- ក្នុងករណីដែលស្ថាប័នទទួលជួលស្ថាប័នគាំទ្រចុះបញ្ជី (សូមមើលទំព័រ15)អោយអនុវត្តផែនការគាំទ្រទាំងស្រុងនោះគេចាត់ទុកថាមានរចនាសម្ព័ន្ធគាំទ្រជនបរទេស។
- ស្ថាប័នគាំទ្រចុះបញ្ជីមិនអាចយកការងារអនុវត្តន៍កាតព្វកិច្ចគាំទ្រដែលត្រូវបានគេជួល ទៅជួលអោយអ្នកដទៃបន្តទៀតបានឡើយ។ (អាចជួលអ្នកបកប្រែភាសាជាដើមដើម្បីធ្វើជាជំនួយការក្នុងការអនុវត្តន៍កាតព្វកិច្ចគាំទ្រ)

# ទិដ្ឋភាពទូទៅនៃផែនការគាំទ្រ (2)



### (1) សេចក្តីណែនាំជាមុន

▪ក្រោយចុះកិច្ចសន្យាការងារ មុននឹងស្នើសុំលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ ឬមុននឹងស្នើសុំការអនុញ្ញាតប្តូរលក្ខណៈសម្បត្តិស្នាក់នៅ ត្រូវធ្វើការពន្យល់ដោយជួបផ្ទាល់ឬតាមរយៈទូរសព្ទមានវីឌីអូធ្វើកាពន្យល់អំពីលក្ខខណ្ឌការងារ ខ្លឹមសារនៃការងារ នីតិវិធីអន្តោប្រវេសន៍ មានការយកប្រាក់ធានារ៉ាប់រងឬអត់ជាដើម។






### (2) ការទៅទទួលនិងជូនទៅមកពេលចេញចូលប្រទេសជប៉ុន

▪ការជូនពីព្រលានយន្តហោះជាដើមទៅកន្លែងធ្វើការឬទៅកន្លែងស្នាក់នៅនៅពេលចូលប្រទេសជប៉ុន

▪ការជូនឬអមដំណើរទៅដល់កន្លែងត្រួតពិនិត្យសុវត្ថិភាពនៅព្រលានយន្តហោះនៅពេលត្រឡប់ទៅប្រទេសវិញ





### (3) ការគាំទ្រដល់ការរកកន្លែងស្នាក់នៅនិងកិច្ចសន្យាដែលចាំបាច់សំរាប់ជីវភាពរស់នៅ

▪ធ្វើជាអ្នកធានារួមគ្នា ឬផ្តល់កន្លែងស្នាក់នៅរបស់ក្រុមហ៊ុន។ល។

▪ណែនាំនិងជួយដល់ការបើកគណនីធនាគារជាដើម ការធ្វើកិច្ចសន្យាទូរសព្ទដៃ ទឹក ភ្លើង ហ្គាសជាដើម









### (4) ការណែនាំអំពីរបៀបរបបរស់នៅ

▪ធ្វើការពន្យល់អំពីច្បាប់ សុជរធម៌ វិធីប្រើនិងលេខទំនាក់ទំនងនៃស្ថាប័នសាធារណៈរបស់ប្រទេសជប៉ុន វិធីឆ្លើយតបពេលមានគ្រោះអាសន្នជាដើម ដើម្បីអោយអាចរស់នៅបានដោយរលូនក្នុងសង្គម។







### (5) ការជូនទៅធ្វើនីតិវិធីសាធារណៈជាដើម

▪អមដំណើរ ឬជួយធ្វើឯកសារសំរាប់នីតិវិធីចុះឈ្មោះកន្លែងស្នាក់នៅ សន្តិសុខសង្គម ពន្ធជាដើមទៅតាមការចាំបាច់






### (6) ការផ្តល់ឱកាសសិក្សាភាសាជប៉ុន

▪ណែនាំអោយទៅចុះឈ្មោះនៅសាលាបង្រៀនភាសាជប៉ុនជាដើម ផ្តល់ព័ត៌មានអំពីសៀវភៅសិក្សាភាសាជប៉ុនជាដើម






### (7) ការឆ្លើយតបនឹងការពិគ្រោះយោបល់ ឬការត្អូញត្អែរ

▪ទាក់ទងនឹងការពិគ្រោះយោបល់ ឬការត្អូញត្អែរនៅកន្លែងធ្វើការឬនៅកន្លែងស្នាក់នៅ ធ្វើការឆ្លើយតប ផ្តល់យោបល់ទៅតាមខ្លឹមសារ ណែនាំដោយភាសាដែលជនបរទេសអាចយល់បានគ្រប់គ្រាន់។ល។



### (8) ការជំរុញការប្រាស្រ័យទាក់ទងជាមួយជនជាតិជប៉ុន

▪កន្លែងប្រាស្រ័យទាក់ទងជាមួយពលរដ្ឋក្នុងសហគមន៍ឬភូមិស្រុកជាដើម ជូនដំណឹងអំពីពិធីបុណ្យក្នុងតំបន់ ផ្តល់ជំនួយអោយចូលរួម។ល។







### (9) ការគាំទ្រដល់ការប្តូរការងារ(ក្នុងករណីកាត់បន្ថយកំលាំងពលកម្មជាដើម)

▪ត្រូវជួយស្វែងរកកន្លែងធ្វើការថ្មីក្នុងករណីដែលអ្នកទទួលមានមូលហេតុត្រូវបញ្ចប់កិច្ចសន្យាការងារ បន្ថែមពីលើការជួយសរសេរលិខិតអនុសាសន៍ជាដើម ត្រូវផ្តល់ការសំរាកដោយគិតកំរៃ និងព័ត៌មានអំពីនីតិវិធីរដ្ឋបាលចាំបាច់ដើម្បីធ្វើសកម្មភាពស្វែងរកការងារ



### (10) ការសម្ភាសន៍ជាប្រចាំ និងការជូនដំណឹងទៅស្ថាប័នរដ្ឋបាល

▪អ្នកទទួលខុសត្រូវក្នុងការគាំទ្រជាដើម ធ្វើការសម្ភាសន៍ជាមួយជនបរទេសនិងថ្នាក់លើរបស់គេជាប្រចាំ(លើសពី1ដងក្នុងអំឡុងពេល3ខែ) ក្នុងករណីមានការល្មើសច្បាប់ស្តង់ដារការងារជាដើម ត្រូវជូនដំណឹង



# តើអ្វីទៅជាស្ថាប័នគាំទ្រចុះបញ្ជី?




## អ្វីទៅជាស្ថាប័នគាំទ្រចុះបញ្ជី?

- ○ ស្ថាប័នគាំទ្រចុះបញ្ជីតាមរយៈការចុះកិច្ចសន្យាជួលអោយគាំទ្រជំនួសស្ថាប័នទទួល ធ្វើការអនុវត្តន៍ការគាំទ្រយោងតាមផែនការគាំទ្រទាំងអស់។
- ○ ដើម្បីក្លាយជាស្ថាប័នគាំទ្រចុះបញ្ជី ត្រូវទទួលការចុះបញ្ជីពីអគ្គនាយកភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន។
- ○ ស្ថាប័នដែលបានទទួលការចុះបញ្ជី ត្រូវបានកត់ត្រាចូលក្នុងបញ្ជីស្ថាប័នគាំទ្រចុះបញ្ជី និងត្រូវបានបិទផ្សាយលើគេហទំព័ររបស់ភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន។
- ○ រយៈពេលចុះបញ្ជីគឺមាន5ឆ្នាំ ហើយអាចបន្តទៀតបាន។
- ○ ត្រូវបង់ថ្លៃសេវាស្នើសុំដើម្បីចុះបញ្ជី។ (ការចុះបញ្ជីថ្មី28,400 យ៉េន ការសុំបន្តការចុះបញ្ជី11,100យ៉េន)
- ○ ស្ថាប័នគាំទ្រចុះបញ្ជីត្រូវធ្វើការជូនដំណឹងគ្រប់ប្រភេទតាមពេលកំណត់ឬពេលចាំបាច់ទៅកាន់អគ្គនាយកភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន។

ចំណុចសំខាន់

○ ស្ថាប័នទទួលនិងស្ថាប័នគាំទ្រចុះបញ្ជីត្រូវធ្វើការជូនដំណឹងគ្រប់ប្រភេទតាមពេលកំណត់ឬពេលចាំបាច់ទៅកាន់អគ្គនាយកភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍ជប៉ុន។

○ ក្នុងករណីខកខានមិនបានជូនដំណឹងឬជូនដំណឹងក្លែងបន្លំ ជាកម្មវត្ថុត្រូវទទួលទោស។

■ **ការជូនដំណឹងរបស់ស្ថាប័នទទួល** *ករណីល្មើសជាកម្មវត្ថុត្រូវណែនាំឬពិន័យ

[ការជូនដំណឹងនៅពេលចាំបាច់]

・ការជូនដំណឹងអំពីការផ្លាស់ប្តូរកិច្ចសន្យា បញ្ចប់កិច្ចសន្យា ការចុះកិច្ចសន្យាថ្មីអំពីការងារពលករជំនាញ

・ការជូនដំណឹងអំពីការផ្លាស់ប្តូរផែនការគាំទ្រ

・ការជូនដំណឹងអំពីការចុះកិច្ចសន្យា ផ្លាស់ប្តូរកិច្ចសន្យា បញ្ចប់កិច្ចសន្យាជួលជាមួយស្ថាប័នគាំទ្រចុះបញ្ជី

・ការជូនដំណឹងនៅពេលមានការលំបាកទទួលយកពលករជំនាញបរទេស

・ការជូនដំណឹងនៅពេលដឹងអំពីការប្រព្រឹត្តិខុសនឹងច្បាប់ទាក់ទងនឹងច្បាប់អន្តោប្រវេសន៍ឬច្បាប់ការ

[ការជូនដំណឹងតាមពេលកំណត់]

・ការជូនដំណឹងអំពីស្ថានភាពនៃការទទួលយកពលករជំនាញបរទេស (ឧទាហរណ៍ ៖ ចំនួនពលករជំនាញបរទេសដែលបានទទួលយកសរុប ព័ត៌មានអំពីឈ្មោះជាដើម ចំនួនថ្ងៃធ្វើការ ទីកន្លែង ខ្លឹមសារការងារ។ល។)

・ការជូនដំណឹងអំពីស្ថានភាពនៃការអនុវត្តន៍ផែនការគាំទ្រ (ឧទាហរណ៍ ៖ ខ្លឹមសារនៃការពិគ្រោះនិងលទ្ធផលនៃការឆ្លើយតបជាដើម) *លើកលែងតែក្នុងករណីជួលស្ថាប័នគាំទ្រចុះបញ្ជីអោយអនុវត្តផែនការគាំទ្រទាំងអស់

・ ការជូនដំណឹងអំពីស្ថានភាពនៃការងាររបស់ពលករជំនាញបរទេស (ឧទាហរណ៍ ៖ ស្ថានភាពនៃការបើកប្រាក់កំរៃ ចំនួនអ្នកលាឈប់ ចំនួនអ្នកបាត់ខ្លួន ចំនួនទឹកប្រាក់ចំណាយសំរាប់ការទទួលយក។ល។)

■ **ការជូនដំណឹងរបស់ស្ថាប័នគាំទ្រចុះបញ្ជី** *ករណីល្មើសជាកម្មវត្ថុត្រូវណែនាំឬលុបចេញពីបញ្ជី

[ការជូនដំណឹងនៅពេលចាំបាច់]

・ ការជូនដំណឹងអំពីប្រការសុំផ្លាស់ប្តូរលើការចុះបញ្ជី

・ការជូនដំណឹងអំពីការផ្អាកឬបញ្ឈប់ការងារគាំទ្រ

[ការជូនដំណឹងតាមពេលកំណត់]

・ ការជូនដំណឹងអំពីស្ថានភាពនៃការអនុវត្តន៍ការងារគាំទ្រ (ឧទាហរណ៍ ៖ ឈ្មោះពលករជំនាញបរទេសជាដើម ឈ្មោះស្ថាប័នទទួលជាដើម ខ្លឹមសារនៃការពិគ្រោះរបស់ពលករជំនាញបរទេសនិងលទ្ធផលនៃការឆ្លើយតបជាដើម)

[ការជូនដំណឹងតាមពេលកំណត់] *ស្ថាប័នទទួល និងស្ថាប័នគាំទ្រចុះបញ្ជី
○ត្រូវជូនដំណឹងក្នុងអំឡុងពេលចាប់ពីថ្ងៃដំបូងដល់ថ្ងៃទី14នៃត្រីមាសបន្ទាប់សំរាប់រាល់ត្រីមាស

(1) ត្រីមាសទី1 ៖ ពីថ្ងៃទី1ខែមករា ដល់ ថ្ងៃទី31ខែមីនា
(2) ត្រីមាសទី2 ៖ ពីថ្ងៃទី1ខែមេសា ដល់ ថ្ងៃទី31ខែមិថុនា
(3) ត្រីមាសទី3 ៖ ពីថ្ងៃទី1ខែកក្កដា ដល់ ថ្ងៃទី31ខែកញ្ញា
(4) ត្រីមាសទី4 ៖ ពីថ្ងៃទី1ខែតុលា ដល់ ថ្ងៃទី31ខែធ្នូ

# អំពីគណៈកម្មាធិការនៃវិស័យនិមួយៗរបស់ពលករជំនាញ



## ចំណុចសំខាន់

- ○ ដើម្បីសម្រេចអោយបាននូវការអនុវត្តន៍ប្រព័ន្ធអោយបានត្រឹមត្រូវ ក្រសួងមានសមត្ថកិច្ចលើវិស័យនិមួយៗបង្កើតគណៈកម្មាធិការសំរាប់វិស័យនិមួយៗ។
- ○ នៅក្នុងគណៈកម្មាធិការ សមាជិកទាំងអស់សហការគ្នាស្អិតល្មួត ផ្តល់ដំណឹងអំពីប្រព័ន្ធឬព័ត៌មាន ជំរុញការគោរពច្បាប់ ក្តាប់អោយបាននូវព័ត៌មានអំពីកង្វះពលកម្មតាមតំបន់និមួយៗ ធ្វើការឆ្លើយតបដែលចាំបាច់ ធ្វើយ៉ាងណាអោយម្ចាស់សហគ្រាសនៅគ្រប់តំបន់ទាំងអស់អាចទទួលយកបានពលករជំនាញបរទេសដែលត្រូវការ។

## រូបភាពបង្ហាញ




## ខ្លឹមសារនៃសកម្មភាព

- ○ ការជូនដំណឹងអំពីចំណុចសំខាន់នៃប្រព័ន្ធទាក់ទងនឹងការទទួលយកពលករជំនាញបរទេស និងគំរូល្អៗ
- ○ ជំរុញការគោរពច្បាប់ទៅដល់ស្ថាប័នពាក់ព័ន្ធនឹងពលករជំនាញ
- ○ ការក្តាប់និងវិភាគលើព័ត៌មានអំពីការប្រែប្រួលនៃស្ថានភាពនិយោជន៍និងស្ថានភាពសេដ្ឋកិច្ច
- ○ ការក្តាប់និងវិភាគលើស្ថានភាពនៃកង្វះពលកម្មតាមតំបន់និមួយៗ
- ○ ពិភាក្សានិងចាត់វិធានការដោះស្រាយទាក់ទងនឹងការបញ្ចៀសការប្រមូលផ្តុំនៅទីក្រុងធំៗជាដើម ដោយផ្អែកលើស្ថានភាពនៃកង្វះពលកម្ម និងស្ថានភាពនៃការទទួលយក (រួមទាំងការស្នើសុំចាំបាច់ទៅសមាជិកជាដើមផង ក្នុងករណីដែលគេទទួលស្គាល់ថាមានការប្រមូលផ្តុំខ្លាំងនៅតំបន់ណាមួយ)
- ○ ការចែករំលែកនិងពិភាក្សាព័ត៌មានផ្សេងៗ បញ្ហាប្រឈមជាដើមដែលចាំបាច់ដើម្បីអោយការអនុវត្តន៍ការទទួលយកធ្វើទៅដោយរលូននិងត្រឹមត្រូវ

សំគាល់៖ ចំពោះវិស័យសំណង់ គេតម្រូវអោយស្ថាប័នទទួលចូលក្នុងនិតិបុគ្គលដែលបង្កើតឡើងរួមគ្នាដោយសមាគមសហគ្រាសសំណង់ ហើយនិតិបុគ្គលនេះជាសមាជិកនៃគណៈកម្មាធិការ។

## គោលការណ៍មូលដ្ឋានរបស់រដ្ឋាភិបាល (សេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ថ្ងៃទី25 ខែធ្នូ ឆ្នាំ2018)

ចាត់វិធានការចាំបាច់ដូចជាធ្វើកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋាភិបាល ដើម្បីទប់ស្កាត់កុំអោយមានការជ្រៀតចូលនៃភ្នាក់ងារអន្តរការអាក្រក់ដូចជាការយកប្រាក់ធានាជាដើម

## ការផ្តួចផ្តើមគ្រប់ជ្រុងជ្រោយ (សេចក្តីសម្រេចរបស់រដ្ឋមន្ត្រី ថ្ងៃទី25 ខែធ្នូ ឆ្នាំ2018)

○ ការផ្តួចផ្តើមដើម្បីជំរុញការទទួលយកធនធានមនុស្សបរទេសអោយបានរលូននិងត្រឹមត្រូវ៖ ការលុបបំបាត់ភ្នាក់ងារអន្តរការអាក្រក់ ក្នុងគោលបំណងលុបបំបាត់ភ្នាក់ងារអន្តរការអាក្រក់ជាមួយប្រទេសចំនួន៩ ដែលមានការប្រឡងភាសាជប៉ុន និងអាចរំពឹងថានឹងបញ្ជូនពលករបរទេស (ខាងក្រោមហៅថា"ប្រទេសអាទិភាពទាំង៩") ដោយរៀបចំកិច្ចព្រមព្រៀងទ្វេភាគីរវាងរដ្ឋាភិបាលជាដើមដែលបង្កើតជាមធ្យោបាយចែករំលែកព័ត៌មាន ហើយទៅតាមភាពចាំបាច់ ជំរុញការចរចាជាមួយប្រទេសដទៃទៀតក្រៅពីប្រទេសខាងលើដែលអាចរំពឹងថានឹងបញ្ជូនពលករ តាមរយៈកិច្ចព្រងព្រៀងទ្វេភាគីដូចគ្នា។

## ចំណុចសំខាន់នៃMOC

○ ការចែករំលែកព័ត៌មាន
ចែករំលែកអោយបានឆាប់រហ័សនូវព័ត៌មានដែលចាំបាច់ឬមានប្រយោជន៍ក្នុងការសម្រេចអោយបាននូវការបញ្ជូននិងការទទួលពលករជំនាញបរទេសអោយបានរលូននិងត្រឹមត្រូវ។នៅក្នុងព័ត៌មានទាំងនេះរួមមានទាំងព័ត៌មានទាក់ទងនឹងអំពើធ្វើឡើងដោយស្ថាប័នទាំងពីរប្រទេសពាក់ព័ន្ធការជ្រើសរើសបុគ្គលិក ការជ្រើសរើសការងាររបស់ពលករជំនាញបរទេសផង។

● ការយកប្រាក់ធានា ការកំណត់ប្រាក់សំណងសំរាប់ការល្មើសកិច្ចសន្យា អំពើរំលោភសិទ្ធិមនុស្ស ការធ្វើអំពើក្លែងបន្លំឯកសារជាដើម ការយកថ្លៃដោយមិនសមស្រប។ល។

○ ការពិភាក្សាដើម្បីកែតម្រូវបញ្ហា
ធ្វើការពិភាក្សានៅពេលចាំបាច់ឬតាមពេលកំណត់ ខិតខំកែតម្រូវបញ្ហាដែលមើលឃើញថាចាំបាច់ត្រូវកែតម្រូវ ដើម្បីអោយការអនុវត្តន៍ប្រព័ន្ធនេះមានភាពត្រឹមត្រូវ។

## ទិដ្ឋភាពនៃកិច្ចព្រមព្រៀងទ្វេភាគី MOC




## ហត្ថលេខី (11ប្រទេស)

(ស្ថិតិគិតត្រឹមចុងខែ12 ឆ្នាំ2019 អក្សរដិតខ្មៅគឺប្រទេសដែលបានចុះMOC ដែលមានវិធានការគ្រប់ជ្រុងជ្រោយ)

**ហ្វីលីពីន** (មីនា 19) **កម្ពុជា** (មីនា 25) **នេប៉ាល់** (មីនា 25) **ភូមា** (មីនា 28) **ម៉ុងហ្គោល** (មេសា 17) ស្រីលង្កា (មិថុនា 19) **ឥណ្ឌូនេស៊ី** (មិថុនា 25) **វៀតណាម** (ប្តូរឯកសារទៅវិញទៅមក កក្កដា 1) បង់ក្លាដេស (សីហា 27) អ៊ូសបេគីស្ថាន (ធ្នូ 17) ប៉ាគីស្ថាន (ធ្នូ 23)

## អំពីស្ថានភាពនៃការអនុញ្ញាតទាក់ទងនឹងពលករជំនាញ(ស្ថិតិត្រឹមបំណាច់ខែធ្នូឆ្នាំ2019៖ តួលេខបឋម)

① ការចេញលិខិតបញ្ជាក់ការទទួលស្គាល់លក្ខណៈសម្បត្តិស្នាក់នៅ 1,139 ករណី

② ការអនុញ្ញាតប្តូរប្រភេទលក្ខណៈសម្បត្តិស្នាក់នៅ 1,062 ករណី

③ ការចុះបញ្ជីស្ថាប័នគាំទ្រចុះបញ្ជី 3,451 ករណី

④ ការផ្តល់ "សកម្មភាពកំណត់" ក្រោមវិធានការពិសេស 857 ករណី

(រួមទាំងករណីមិនទាន់ផ្តល់)

### បំណែងចែកនៃស្ថាប័នគាំទ្រចុះបញ្ជី




### បំណែងចែកករណីផ្តល់អោយ




## ចំនួនពលករជំនាញ (គិតត្រឹម ចុងខែវិច្ឆិកា ឆ្នាំ2019 តួលេខបឋម)




1,019 people

| វិស័យ | ចំនួននាក់ |
|---|---|
| ការថែទាំមនុស្ស | 19 |
| ការសម្អាតអគារ | 12 |
| ឧស្សាហកម្មផលិតគ្រឿងបន្លាស់ និងគ្រឿងឧបករណ៍ | 143 |
| ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម | 151 |
| ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិចនិងព័ត៌មាន | 31 |
| ការងារសំណង់ | 59 |
| ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា | 32 |
| ការជួសជុលរថយន្ត | 8 |
| ការងារអាកាសចរណ៍ | 0 |
| ការស្នាក់នៅ | 13 |
| កសិកម្ម | 169 |
| នេសាទ និងវារីវប្បកម្ម | 8 |
| ការផលិតអាហារ និងភេសជ្ជៈ | 303 |
| ឧស្សាហកម្មភោជនីយដ្ឋាន | 71 |

# ស្ថានភាពនៃការអនុវត្តន៍ប្រព័ន្ធពលករជំនាញ (2)



## ការអនុវត្តន៍ការប្រឡងសំរាប់ពលករជំនាញជាដើម (គិតត្រឹមចុងខែធ្នូ ឆ្នាំ2019 យោងតាមគេហទំព័ររបស់ស្ថាប័នប្រឡងនិមួយៗ)

| | ទីតាំង (ខែ) | ចំនួនបេក្ខជន | ចំនួនជាប់ | គម្រោងអនាគត (សំគាល់ 1) |
|---|---|---|---|---|
| ការថែទាំមនុស្ស | (ហ្វីលីពីន) មេសា-ធ្នូ 2019<br>(កម្ពុជា) កញ្ញា-ធ្នូ2019<br>(ឥណ្ឌូនេស៊ី) តុលា-ធ្នូ 2019<br>(នេប៉ាល់) តុលា-ធ្នូ 2019<br>(ម៉ុងហ្គោល) វិច្ឆិកា, ធ្នូ 2019<br>(ក្នុងប្រទេសជប៉ុន) តុលា-ធ្នូ 2019 | (ការប្រឡងជំនាញបច្ចេកទេស)<br>2,634 នាក់(សំគាល់ 2)<br>ការប្រឡងភាសាជប៉ុន<br>2,612 នាក់ (សំគាល់ 2) | (ការប្រឡងជំនាញបច្ចេកទេស)<br>1,254 នាក់ (សំគាល់ 2)<br>ការប្រឡងភាសាជប៉ុន<br>1,285 នាក់ (សំគាល់ 2) | (ហ្វីលីពីន) មករា 2020<br>(កម្ពុជា) មករា 2020<br>(ឥណ្ឌូនេស៊ី) មករា 2020<br>(នេប៉ាល់) មករា 2020 |
| ការសម្អាតអគារ | (ភូមា) ធ្នូ 2019<br>(ក្នុងប្រទេសជប៉ុន) វិច្ឆិកា, ធ្នូ 2019 | 472 នាក់ | 317 នាក់ | — |
| ឧស្សាហកម្មផលិតគ្រឿងបន្លាស់ និងគ្រឿងឧបករណ៍ (សំគាល់ 3)<br>ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម (សំគាល់ 3)<br>ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិចនិងព័ត៌មាន (សំគាល់ 3) | — | — | — | (ឥណ្ឌូនេស៊ី) មករា 2020 |
| ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា (សំគាល់ 3) | (ហ្វីលីពីន) វិច្ឆិកា 2019 | (សំគាល់ 2) | (សំគាល់ 2) | — |
| ការជួសជុលរថយន្ត | (ហ្វីលីពីន) ធ្នូ 2019 | 12 នាក់ | 12 នាក់ | (ហ្វីលីពីន) មករា-មីនា 2020 |
| ការងារអាកាសចរណ៍ (សំគាល់ 3) | (ហ្វីលីពីន) វិច្ឆិកា 2019<br>(ម៉ុងហ្គោល) តុលា 2019<br>(ក្នុងប្រទេសជប៉ុន) វិច្ឆិកា 2019 | 227 នាក់ | 128 នាក់ | (ក្នុងប្រទេសជប៉ុន) កុម្ភៈ 2020 |
| ការស្នាក់នៅ | (ភូមា) តុលា 2019<br>(ក្នុងប្រទេសជប៉ុន) មេសា-តុលា 2019 | 1,280 នាក់ | 728 នាក់ | (ក្នុងប្រទេសជប៉ុន) មករា 2020 |
| កសិកម្ម (សំគាល់ 3) | (ហ្វីលីពីន) តុលា-ធ្នូ 2019 | 9 នាក់ (សំគាល់ 2) | 9 នាក់ (សំគាល់ 2) | (ហ្វីលីពីន) មករា-មីនា 2020<br>(កម្ពុជា) មករា-មីនា 2020<br>(ឥណ្ឌូនេស៊ី) មករា-មីនា 2020 |
| នេសាទ និងវារីវប្បកម្ម (សំគាល់ 3) | — | — | — | (ឥណ្ឌូនេស៊ី) មករា 2020 |
| ការផលិតអាហារ និងភេសជ្ជៈ | (ហ្វីលីពីន) វិច្ឆិកា, ធ្នូ 2019<br>(ក្នុងប្រទេសជប៉ុន) តុលា 2019 | 626 នាក់ (សំគាល់ 2) | 433 នាក់ (សំគាល់ 2) | (ហ្វីលីពីន) មករា-មីនា 2020<br>(ឥណ្ឌូនេស៊ី) មករា-មីនា 2020<br>(ក្នុងប្រទេសជប៉ុន) កុម្ភៈ 2020 |
| ឧស្សាហកម្មភោជនីយដ្ឋាន | (ហ្វីលីពីន) វិច្ឆិកា, ធ្នូ 2019<br>(ក្នុងប្រទេសជប៉ុន) មេសា, មិថុនា, កញ្ញា, វិច្ឆិកា 2019 | 4,717 នាក់ (សំគាល់ 2) | 2,966 នាក់ (សំគាល់ 2) | (ហ្វីលីពីន) មករា-មីនា 2020<br>(កម្ពុជា) មករា-មីនា 2020<br>(ក្នុងប្រទេសជប៉ុន) កុម្ភៈ 2020 |
| មូលនិធិជប៉ុន<br>ការប្រឡងភាសាជប៉ុនមូលដ្ឋាន | (ហ្វីលីពីន) មេសា-មិថុនា, សីហា-វិច្ឆិកា 2019<br>(កម្ពុជា) តុលា 2019<br>(ឥណ្ឌូនេស៊ី) តុលា, វិច្ឆិកា 2019<br>(នេប៉ាល់) តុលា, វិច្ឆិកា 2019<br>(ម៉ុងហ្គោល) វិច្ឆិកា 2019 | 2,279 នាក់ | 779 នាក់ | (ហ្វីលីពីន) មករា 2020<br>(កម្ពុជា) មករា 2020<br>(ឥណ្ឌូនេស៊ី) មករា 2020<br>(នេប៉ាល់) មករា 2020 |

សំគាល់1៖ គម្រោងអនុវត្តន៍ក្រោយខែមករា ឆ្នាំ2020 អាចនឹងប្រែប្រួល
សំគាល់2៖ ចំនួនបេក្ខជនប្រឡងនិងអ្នកជាប់សំរាប់ ការថែទាំមនុស្ស (ការប្រឡងជំនាញបច្ចេកទេសនិងការប្រឡងភាសាជប៉ុន ) ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា កសិកម្ម ការផលិតអាហារនិងភេសជ្ជៈ ឧស្សាហកម្មភោជនីយដ្ឋាន ក្រោយខែវិច្ឆិកា មិនទាន់ត្រូវបានដាក់ចេញ និងមិនត្រូវបានរាប់ចូលក្នុងចំនួនសរុបទេ។
សំគាល់3៖ ស្ថានភាពនៃការអនុវត្តន៍ខុសគ្នាតាមផ្នែកការងារ

# អំពីគោលការណ៍មូលដ្ឋាន និងបញ្ញត្តិរបស់ក្រសួងមានសមត្ថកិច្ចជាដើម

# ទិដ្ឋភាពទូទៅនៃគោលការណ៍មូលដ្ឋានអំពីការអនុវត្តន៍ប្រព័ន្ធទាក់ទងនឹងលក្ខណៈសម្បត្តិស្នាក់នៅពលករជំនាញ

**ជាគោលការណ៍មូលដ្ឋានអំពីការអនុវត្តន៍ប្រព័ន្ធទាក់ទងនឹងលក្ខណៈសម្បត្តិស្នាក់នៅពលករជំនាញ ដែលត្រូវបានដាក់ចេញដើម្បីសម្រេចអោយបាននូវការអនុវត្តន៍ប្រព័ន្ធទាក់ទងនឹងលក្ខណៈសម្បត្តិស្នាក់នៅពលករជំនាញអោយបានត្រឹមត្រូវ (វិសោធនកម្មច្បាប់គ្រប់គ្រងអន្តោប្រវេសន៍និងទទួលស្គាល់ជនភៀសខ្លួន មាត្រាទី២-៣)**

## 1 ប្រការអំពីខ្លឹមសារនៃប្រព័ន្ធ

រៀបចំរចនាសម្ព័ន្ធទទួលយកជនបរទេសដែលមានឯកទេសនិងជំនាញក្នុងកំរិតជាក់លាក់មួយ ហើយអាចបំរើការងារបានក្នុងវិស័យដែលឧស្សាហកម្មមានការលំបាកក្នុងការទាក់ទាញធនធានមនុស្ស ទោះជាបានធ្វើការបង្កើនផលិតភាពនិងសកម្មភាពទាក់ទាញធនធានមនុស្សក្នុងប្រទេស ដើម្បីដោះស្រាយបញ្ហាខ្វះខាតកំលាំងពលកម្មធ្ងន់ធ្ងររបស់អាជីវកម្មខ្នាតតូចនិងមធ្យមជាដើម

## 2 ប្រការអំពីវិស័យឧស្សាហកម្មដែលគួរតែរកអោយបាននូវធនធានមនុស្សខ្វះខាតចេញពីជនបរទេស

➢ វិស័យទទួលយកពលករជំនាញបរទេស

គឺវិស័យដែលឧស្សាហកម្មដែលគួរតែរកអោយបាននូវធនធានមនុស្សខ្វះខាតតាមរយៈជនបរទេស ដោយសារតែស្ថិតក្នុងស្ថានភាពលំបាកក្នុងការទាក់ទាញធនធានមនុស្ស ទោះជាបានធ្វើការបង្កើនផលិតភាពនិងសកម្មភាពទាក់ទាញធនធានមនុស្សក្នុងប្រទេស

| ការងារលើដីនៅព្រលានយន្តហោះ | ការគាំទ្រយន្តហោះលើដី |

10 ការស្នាក់នៅ

| ប្រភេទការងារ | ឈ្មោះការងារ |
|---|---|
| | |

11 កសិកម្ម

| ប្រភេទការងារ | ឈ្មោះការងារ |
|---|---|
| កសិកម្មដាំដុះ | ការដាំដុះដោយប្រើបរិក្ខារ |
| | ការធ្វើចំការ ដាំបន្លែ |
| | ការដាំផ្លែឈើ |
| កសិកម្មចិញ្ចឹមសត្វ | ការចិញ្ចឹមជ្រូក |
| | ការចិញ្ចឹមមាន់ |
| | ការចិញ្ចឹមសត្វយកទឹកដោះ |

12 នេសាទនិងវារីវប្បកម្ម

| ប្រភេទការងារ | ឈ្មោះការងារ |
|---|---|
| ការនេសាទដោយនាវានេសាទ | ការនេសាទត្រី Bonitoដោយសន្ទូច |
| | ការនេសាទដោយសន្ទូចជាជួរ |
| | ការនេសាទមឹក |
| | ការនេសាទដោយអញ្ចងអួន |
| | ការនេសាទដោយអូសចៃវ៉ា |
| | ការនេសាទដោយមងអន្លង់ |
| | ការនេសាទដោយសំណាញ់នៅនឹង |
| | ការនេសាទដោយកន្ត្រកចាប់ក្តាមបង្គា |
| វារីវប្បកម្ម | ការចិញ្ចឹមខ្យងស្កាឡុប អយស្ទ័រ |

13 ការផលិតអាហារ និងភេសជ្ជៈ

| ប្រភេទការងារ | ឈ្មោះការងារ |
|---|---|
| ការបិតកំប៉ុង | ការបិតកំប៉ុង |
| ឧស្សាហកម្មកែច្នៃបសុបក្សី | ការងារកែច្នៃបសុបក្សី |
| ឧស្សាហកម្មផលិតអាហារសមុទ្រកែច្នៃដោយប្រើកំដៅ | ការផលិតប្រភេទរបស់សម្ងួត |
| | ការផលិតផលិតផលសម្ងួតដោយកំដៅ |
| | ការផលិតផលិតផលប្រឡាក់គ្រឿង |
| | ការផលិតគ្រឿងឆ្អើរ |
| ឧស្សាហកម្មផលិតអាហារសមុទ្រកែច្នៃដោយមិនប្រើកំដៅ | ការផលិតគ្រឿងប្រឡាក់អំបិល |
| | ការផលិតអាហារសម្ងួត |
| | ការផលិតអាហារផ្អាប់ |
| ការធ្វើប្រហិតត្រី | ការងារផលិតកាម៉ាបុកុ |
| ឧស្សាហកម្មកែច្នៃសាច់គោ ជ្រូក | ការងារកែច្នៃសាច់គោ ជ្រូក |
| ការផលិតហាំ សាច់ក្រក bacon | ការងារផលិតហាំ សាច់ក្រក bacon |
| ការផលិតនំប៉័ង | ការងារផលិតនំប៉័ង |
| ឧស្សាហកម្មផលិតអាហារឆ្អិនស្រាប់ | ការងារផលិតអាហារឆ្អិនស្រាប់ |
| ឧស្សាហកម្មផលិតជ្រក់កសិផល | ការងារផលិតជ្រក់កសិផល |

14 ឧស្សាហកម្មភោជនីយដ្ឋាន

| ប្រភេទការងារ | ឈ្មោះការងារ |
|---|---|
| ការផលិតអាហារសំរាប់ស្ថាប័នវេជ្ជសាស្ត្រ ថែទាំ | ការងារផលិតអាហារសំរាប់ស្ថាប័នវេជ្ជសាស្ត្រ ថែទាំ |

(សំគាល់) ត្រូវបានបញ្ចូលជាការងារគោលដៅចាប់ពី ថ្ងៃទី16 ខែវិច្ឆិកា ឆ្នាំ2018

# អាស័យដ្ឋានទំនាក់ទំនងអំពីលក្ខណៈសម្បត្តិស្នាក់នៅ “ពលករជំនាញ” (ក្រសួងយុត្តិធម៌)

(អំពីប្រព័ន្ធទូទៅ នីតិវិធីចូលប្រទេស និងស្នាក់នៅ អំពីស្ថាប័នគាំទ្រចុះបញ្ជី)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់សាប់ប៉ូរ៉ូ | ផ្នែកកិច្ចការទូទៅ<br>អគាររដ្ឋបាលរួមសាប់ប៉ូរ៉ូទី3<br>12 Odori-Nishi, Chuo-ku, Sapporo City, Hokkaido | 011-261-7502 |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់សេនដៃ | ផ្នែកកិច្ចការទូទៅ<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់សេនដៃទី2<br>1-3-20 Gorin, Miyagino-ku, Sendai City, Miyagi | 022-256-6076 |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់តូក្យូ | 5-5-30 Konan, Minato-ku, Tokyo<br>ផ្នែកត្រួតពិនិត្យជំនួញនិងការងារ3 | 0570-034259<br>(លេខតំណ 330) |
| ការិយាល័យរងសេវាកម្មអន្តោប្រវេសន៍យ៉ុកុហាម៉ា | ផ្នែកកិច្ចការទូទៅ<br>10-7 Torihama-cho, Kanazawa-ku, Yokohama City, Kanagawa | 045-769-1720 (តំណាង) |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់ណាហ្គោយ៉ា | 5-18, Shoho-cho, Minato-ku, Nagoya City, Aichi<br>(ទាក់ទងនឹងការទទួល សហគ្គិភាព)<br>ផ្នែកគ្រប់គ្រងការត្រួតពិនិត្យ<br>(ទាក់ទងនឹងលក្ខណៈសម្បត្តិស្នាក់នៅ “ពលករជំនាញ”)<br>ផ្នែកត្រួតពិនិត្យជំនួញនិងការងារទី2 | ផ្នែកគ្រប់គ្រងការត្រួតពិនិត្យ<br>052-559-2112<br>ផ្នែកត្រួតពិនិត្យជំនួញនិងការងារទី2<br>052-559-2110 |

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់អូសាកា | ផ្នែកកិច្ចការទូទៅ<br>1-29-53 Nankou Kita, Suminoe-ku, Osaka City, Osaka | 06-4703-2110 |
| ការិយាល័យរងសេវាកម្មអន្តោប្រវេសន៍កូបេ | ផ្នែកកិច្ចការទូទៅ<br>អគាររដ្ឋបាលរួមតំបន់កូបិ<br>29 Kaigan-dori, Chuo-ku, Kobe City, Hyogo | 078-391-6377 (តំណាង) |
| ការិយាល័យអន្តោប្រវេសន៍តំបន់ហ៊ីរ៉ូស៊ីម៉ា | ផ្នែកត្រួតពិនិត្យការងារ និងការស្នាក់នៅអចិន្ត្រៃយ៍<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់ហ៊ីរ៉ូស៊ីម៉ា<br>2-31 Kami-hacchobori, Naka-ku, Hiroshima City, Hiroshima | 082-221-4412 (តំណាង) |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់តាកាម៉ាត្ស៊ូ | ផ្នែកកិច្ចការទូទៅ<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់តាកាម៉ាត្ស៊ូ<br>1-1 Marunouchi, Takamatsu City, Kagawa | 087-822-5852 |
| ការិយាល័យសេវាកម្មអន្តោប្រវេសន៍តំបន់ហ្វីគុអុកា | ផ្នែកកិច្ចការទូទៅ<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់ហ្វីគុអុកាទីI<br>3-5-25 Maizuru, Chuo-ku, Fukuoka City, Fukuoka | 092-717-5420 |
| ការិយាល័យរងសេវាកម្មអន្តោប្រវេសន៍ណាហា | ផ្នែកត្រួតពិនិត្យ<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់ណាហាទីI<br>1-15-15 Higawa, Naha City, Okinawa | 098-832-4186 |

យោងៈ គេហទំព័ររបស់ក្រសួងយុត្តិធម៌ “ការទទួលយកពលករបរទេសថ្មី (ការបង្កើតលក្ខណៈសម្បត្តិស្នាក់នៅ ពលករជំនាញ)”
http://www.moj.go.jp/nyuukokukanri/kouhou/ny

# អាស័យដ្ឋានទំនាក់ទំនងអំពីលក្ខណៈសម្បត្តិស្នាក់នៅ “ពលករជំនាញ”

(ឧស្សាហកម្មផលិតនាវានិងផ្គត់ផ្គង់គ្រឿងនាវា)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យនាវាចរណ៍នៃ MLIT | 2-1-3 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យឧស្សាហកម្មនាវា | TEL 03-5253-8634 |
| ការិយាល័យដឹកជញ្ជូន Hokkaido | 10 Odori Nishi, Chuo-ku, Sapporo, Hokkaido<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 011-290-1012 |
| ការិយាល័យដឹកជញ្ជូន Tohoku | 1 Teppocho, Miyagino-ku, Sendai, Miyagi<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 022-791-7512 |
| ការិយាល័យដឹកជញ្ជូន Kanto | 5-57 Kitanakadori, Naka-ku, Yokohama, Kanagawa<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 045-211-7223 |
| ការិយាល័យដឹកជញ្ជូន Hokuriku Shinetsu | 1-2-1 Misaki-cho, Chuo-ku, Niigata City, Niigata<br>ការិយាល័យឧស្សាហកម្មនាវាចរណ៍ផ្នែកនាវាចរណ៍ | TEL 025-285-9156 |
| ការិយាល័យដឹកជញ្ជូន Chubu | 2-2-1 San-nomaru, Naka-ku, Nagoya, Aichi<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 052-952-8020 |
| ការិយាល័យដឹកជញ្ជូន Kinki | 4-1-76 Otemae, Chuo-ku, Osaka City, Osaka<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 06-6949-6425 |
| ការិយាល័យគ្រប់គ្រងការដឹកជញ្ជូន Kobe | 1-1 Hatobamachi, Chuo-ku, Kobe, Hyogo<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 078-321-3148 |
| ការិយាល័យដឹកជញ្ជូន Chugoku | 6-30 Kami-hacchobori, Naka-ku, Hiroshima City, Hiroshima<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 082-228-3691 |
| ការិយាល័យដឹកជញ្ជូន Shikoku | 3-33 Sunport Takamatsu, Kagawa<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 087-802-6816 |
| ការិយាល័យដឹកជញ្ជូន Kyushu | 2-11-1 Hakata Station East, Hakata-ku, Fukuoka City, Fukuoka<br>ការិយាល័យអ្នកដំណើរនិងឧស្សាហកម្មនាវាផ្នែកជំរុញអាជីវកម្មនាវាចរណ៍ | TEL 092-472-3158 |
| អគ្គលេខាធិការដ្ឋាន Okinawa | 2-1-1 Omoromachi, Naha, Okinawa<br>ការិយាល័យនាវិកផ្នែកដឹកជញ្ជូន | TEL 098-866-1838 |

(ការងារសំណង់)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យឧស្សាហកម្មដីនិងសំណង់នៃ MLIT | 2-1-3 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យរៀបចំទីផ្សារសំណង់ | TEL 03-5253-8283 |
| ការិយាល័យអភិវឌ្ឍន៍ Hokkaido | 8 Nishi 2 Kita-ku, Sapporo<br>ការិយាល័យជំរុញអាជីវកម្ម<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 011-709-2311<br>（ខាងក្នុង៖ 5895） |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Tohoku | 3-3-1 Honcho, Aoba-ku, Sendai<br>ការិយាល័យសំណង់<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 022-263-6131 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Kanto | 2-1 Shintoshin, Chuo-ku, Saitama City, Saitama<br>ការិយាល័យគោលនយោបាយសំណង់<br>ផ្នែកឧស្សាហកម្មសំណង់។ | TEL 048-601-3151 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Hokuriku | 1-1-1 Misaki-cho, Chuo-ku, Niigata City, Niigata<br>ការិយាល័យផែនការសំណង់និង<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 025-370-6571 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Chubu | 2-5-1 Sannomaru, Naka-ku, Nagoya, Aichi<br>ការិយាល័យគោលនយោបាយសំណង់<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 052-953-8572 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Kinki | 1-5-44 Otemae, Chuo-ku, Osaka<br>ការិយាល័យគោលនយោបាយសំណង់<br>ផ្នែកឧស្សាហកម្មសំណង់។ | TEL 06-6942-1071 |

(ការងារសំណង់(ត))

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យអភិវឌ្ឍន៍តំបន់ Chugoku | 2-15 hacchobori, Naka-ku, Hiroshima<br>ការិយាល័យផែនការសំណង់និង<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 082-221-9231 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Shikoku | 3-33 Sunport Takamatsu<br>ការិយាល័យផែនការសំណង់និង<br>ផ្នែកឧស្សាហកម្មសំណង់ | TEL 087-811-8314 |
| ការិយាល័យអភិវឌ្ឍន៍តំបន់ Kyushu | 2-10-7 Hakata Station Higashi, Hakata-ku, Fukuoka City, Fukuoka<br>ការិយាល័យគោលនយោបាយសំណង់និងផ្នែកឧស្សាហកម្មសំណង់ | TEL 092-471-6331<br>(លេខតំណ៖ 6147,6142) |
| អគ្គលេខាធិការដ្ឋាន Okinawa | 2-1-1 Omoromachi, Naha, Okinawa<br>ការិយាល័យអភិវឌ្ឍន៍និងសំណង់<br>ផ្នែកឧស្សាហកម្មសំណង់ និងអភិវឌ្ឍន៍តំបន់ | TEL 098-866-1910 |

(ការស្នាក់នៅ)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ភ្នាក់ងារទេសចរណ៍ MLIT | 2-1-2 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកឧស្សាហកម្មទេសចរណ៍ការិយាល័យគោលនយោបាយធនធានមនុស្សទេសចរណ៍ | TEL 03-5253-8367 |
| ការិយាល័យដឹកជញ្ជូន Hokkaido | 10 Odori Nishi, Chuo-ku, Sapporo, Hokkaido<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 011-290-2700 |
| ការិយាល័យដឹកជញ្ជូន Tohoku | 1 Teppoucho, Miyagino-ku, Sendai, Miyagi<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 022-791-7509 |
| ការិយាល័យដឹកជញ្ជូន Kanto | 5-57 Kitanakadori, Naka-ku, Yokohama, Kanagawa<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 045-211-1255 |
| ការិយាល័យដឹកជញ្ជូន Hokuriku | 1-2-1 Misaki-cho, Chuo-ku, Niigata City, Niigata<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 025-285-9181 |
| ការិយាល័យដឹកជញ្ជូន Chubu | 2-2-1 Sannomaru, Naka-ku, Nagoya, Aichi<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 052-952-8045 |
| ការិយាល័យដឹកជញ្ជូន Kinki | 4-1-76 Otemae, Chuo-ku, Osaka City, Osaka<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 06-6949-6466 |
| ការិយាល័យដឹកជញ្ជូន Chugoku | 6-30 Kami-hacchobori, Naka-ku, Hiroshima City, Hiroshima<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 082-228-8701 |
| ការិយាល័យដឹកជញ្ជូន Shikoku | 3-33 Sunport, Takamatsu, Kagawa<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 087-802-6735 |
| ការិយាល័យដឹកជញ្ជូន Kyushu | 2-11-1 Hakata Station East, Hakata-ku, Fukuoka City, Fukuoka<br>ផ្នែកទេសចរណ៍ការិយាល័យផែនការទេសចរណ៍ | TEL 092-472-2330 |
| អគ្គលេខាធិការដ្ឋាន Okinawa | 2-1-1 Omoromachi, Naha, Okinawa<br>ផ្នែកដឹកជញ្ជូនការិយាល័យផែនការ | TEL 098-866-1812 |

(ការជួសជុលរថយន្ត)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យយានយន្ត MLIT | 2-1-3 Kasumigaseki, Chiyoda-ku, Tokyo | TEL 03-5253-8111<br>(42426、42414) |

(ការងារអាកាសចរណ៍)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យអាកាសចរណ៍ MLIT | 2-1-3 Kasumigaseki, Chiyoda-ku, Tokyo | TEL 03-5253-8111 |
| | ផ្នែកផែនការបណ្ដាញអាកាសចរណ៍<br>ការិយាល័យផែនការបណ្ដាញអាកាសចរណ៍<br>(ការងារលើដីនៅព្រលានយន្តហោះ) | (លេខតំណ៖ 49114) |
| | ផ្នែកសុវត្ថិភាព ការិយាល័យសុវត្ថិភាពអាកាសចរណ៍ គោលនយោបាយយានិក<br>ការិយាល័យគោលនយោបាយ<br>(គ្រប់គ្រងយន្តហោះ) | (លេខតំណ៖ 50137) |

# អាស័យដ្ឋានទំនាក់ទំនងអំពីលក្ខណៈសម្បត្តិស្នាក់នៅ “ពលករជំនាញ”

(កសិកម្ម)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| ការិយាល័យជលផល MAFF | 1-2-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកការងារកសិកម្មនិងស្ត្រី | TEL 03-6744-2162 |
| ការិយាល័យកសិកម្ម Hokkaido | 2-22 South 22 West 6 Chuo-ku, Sapporo, Hokkaido<br>ផ្នែកឧស្សាហកម្មផលិតគ្រប់គ្រង ការិយាល័យបណ្តុះបណ្តាលអ្នកបន្តវេន | TEL 011-330-8809 |
| ការិយាល័យកសិកម្ម Tohoku | 3-3-1 Honcho, Aoba-ku, Sendai, Miyagi<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 022-221-6217 |
| ការិយាល័យកសិកម្ម Kanto | 2-1 Shintoshin, Chuo-ku, Saitama City, Saitama<br>អគាររដ្ឋបាល Saitama លេខ2<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 048-740-0394 |
| ការិយាល័យកសិកម្ម Hokuriku | 2-2-60 Hirosaka, Kanazawa, Ishikawa<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 076-232-4238 |
| ការិយាល័យកសិកម្ម Tokai | 1-2-2 Sannomaru, Naka-ku, Nagoya, Aichi<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 052-223-4620 |
| ការិយាល័យកសិកម្ម Kinki | Nishinotointsu Shimochojamachi, Sagaru Chojiburochou, Kamigyo-ku, Kyoto City, Kyoto<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 075-414-9055 |
| ការិយាល័យកសិកម្ម Chugoku Shikoku | 1-4-1 Shimoishii, Kita-ku, Okayama City, Okayama<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 086-224-8842 |
| ការិយាល័យកសិកម្ម Kyushu | 2-10-1 Kasuga, Nishi-ku, Kumamoto City, Kumamoto<br>ផ្នែកគាំទ្រអាជីវកម្មនិងការគ្រប់គ្រង ការិយាល័យគាំទ្រអាជីវកម្ម | TEL 096-300-6375 |
| អគ្គលេខាធិការដ្ឋាន Okinawa | 2-1-1 Omoromachi, Naha, Okinawa<br>អគាររដ្ឋបាលរួមកិច្ចការច្បាប់ណាហាទី2<br>ផ្នែកគ្រប់គ្រង MAFF | TEL 098-866-1628 |

(នេសាទ និងវារីវប្បកម្ម)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានជលផលនៃ MAFF | 1-2-1 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យផែនការក្រុមពលករជលផល | TEL 03-6744-2340 |

(ការថែទាំមនុស្ស)

| | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានគាំទ្រសង្គមនៃ MHLW | 1-2-2 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យវិធានការធនធានមនុស្សថែទាំមនុស្ស | TEL 03-5253-1111<br>(លេខតំណៈ2125,3146) |

(ឧស្សាហកម្មផលិតម៉ាស៊ីនឧស្សាហកម្ម)

| | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានឧស្សាហកម្មផលិតកម្មនៃ METI | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យម៉ាស៊ីនឧស្សាហកម្ម | TEL 03-3501-1691 |
| (អំពីវិស័យផលិតកម្មទាំង3) | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកកិច្ចការទូទៅ | TEL 03-3501-1689 |

(ឧស្សាហកម្មផលិតគ្រឿងបន្លាស់ និងគ្រឿងឧបករណ៍)

| | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានឧស្សាហកម្មផលិតកម្មនៃ METI | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យឧស្សាហកម្មគ្រឿងបន្លាស់ | TEL 03-3501-1063 |
| (អំពីវិស័យផលិតកម្មទាំង3) | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកកិច្ចការទូទៅ | TEL 03-3501-1689 |

(ឧស្សាហកម្មអគ្គិសនី អេឡិចត្រូនិចនិងព័ត៌មាន)

| | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានព័ត៌មានពាណិជ្ជកម្មនៃ METI | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកឧស្សាហកម្មព័ត៌មាន | TEL 03-3501-6944 |
| (អំពីវិស័យផលិតកម្មទាំង3)<br>នាយកដ្ឋានឧស្សាហកម្មផលិតកម្មនៃ METI | 1-3-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកកិច្ចការទូទៅ | TEL 03-3501-1689 |

(ឧស្សាហកម្មភោជនីយដ្ឋាន)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានឧស្សាហកម្មអាហារនៃ MAFF | 1-2-1 Kasumigaseki, Chiyoda-ku, Tokyo<br>ការិយាល័យវប្បធម៌អាហារ និងការបង្កើតទីផ្សារ | TEL 03-6744-7177 |

(ការផលិតអាហារ និងភេសជ្ជៈ)

| ឈ្មោះការិយាល័យ | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានឧស្សាហកម្មអាហារនៃ MAFF | 1-2-1 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកផលិតកម្មអាហារ | TEL 03-6744-7180 |

(ការសម្អាតអគារ)

| | អាស័យដ្ឋាន/ផ្នែក | លេខទំនាក់ទំនង |
|---|---|---|
| នាយកដ្ឋានឱសថនិងអនាម័យនៃ MHLW | 1-2-2 Kasumigaseki, Chiyoda-ku, Tokyo<br>ផ្នែកសុខភាពនិងអនាម័យ | TEL 03-5253-1111<br>(Ext. 2432) |

# អាសយដ្ឋានទំនាក់ទំនងអំពីលក្ខណៈសម្បត្តិស្នាក់នៅ “ពលករជំនាញ”
## (បញ្ជីទំនាក់ទំនងនៃប្រទេសដែលបានចុះកិច្ចព្រមព្រៀងទ្វេភាគីទាក់ទងនឹងពលករជំនាញ)

| ឈ្មោះប្រទេស | ទំនាក់ទំនង | | | អាសយដ្ឋានជាដើម | | | | ភាសា |
|---|---|---|---|---|---|---|---|---|
| | | | លេខប្រៃសណីយ៍ | អាសយដ្ឋាន | TEL | FAX | អាសយដ្ឋានEmail | |
| ហ្វីលីពីន | នៅជប៉ុន | ស្ថានទូតសាធារណរដ្ឋហ្វីលីពីនប្រចាំនៅប្រទេសជប៉ុន<br>Overseas Labour Office<br>**http://polotokyo.dole.gov.ph/** | 106-8537 | 5-15-5 Roppongi, Minato-ku, Tokyo | 03-6441-0428<br>03-6441-0478 | 03-6441-3436 | polotokyo@gmail.com | អង់គ្លេស ហ្វីលីពីន |
| | នៅបរទេស | Philippine Overseas Employment Administration<br>Pre-Employment Service Office<br>**http://poea.gov.ph/** | 1550 | Blas F. Ople Building<br>Ortigas Avenue corner EDSA<br>Mandaluyong City | +632-722-1162 | - | marketdev@poea.gov.ph | អង់គ្លេស ហ្វីលីពីន |
| កម្ពុជា | នៅជប៉ុន | ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសជប៉ុន | 107-0052 | 8-6-9 Akasaka, Minato-ku, Tokyo | 03-5412-8521<br>080-3459-7889 | 03-5412-8526 | camemb.jpn@mfaic.gov.kh<br>rithy_bbajp@yahoo.com | ជប៉ុន អង់គ្លេស ខ្មែរ |
| | នៅបរទេស | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា | - | Building #3,Russian Federation Blvd., Sangkat Teklaak I, Khan Toulkok Phnom Penh, Kingdom of Cambodia | +855-23880474<br>+855-78449959 | - | sopheakhoung@yahoo.com | អង់គ្លេស ខ្មែរ |
| ម៉ុងហ្គោលី | នៅជប៉ុន | ស្ថានទូតម៉ុងហ្គោលីប្រចាំនៅប្រទេសជប៉ុន | 150-0047 | 21-4 Kamiyamacho, Shibuya-ku, Tokyo | 03-3469-2088 | 03-3469-2216<br>03-3469-2192 | tokyo@mfa.gov.mn | ជប៉ុន អង់គ្លេស ម៉ុងហ្គោលី |
| | នៅបរទេស | General Office for Labour and Social Welfare Services | 17042 | General Office for Labour and Social Welfare Services Building, Chinggis Avenue, 2nd khoroo, Khan-Uul district, Ulaanbaatar city, Mongolia | +976-77121285 | +976-70136990 | ssw@hudulmur-halamj.gov.mn | អង់គ្លេស ម៉ុងហ្គោលី<br>*ភាសាជប៉ុនចាប់មានពីខែកញ្ញា ឆ្នាំ2019 |
| ភូមា | នៅជប៉ុន | ស្ថានទូតសាធារណរដ្ឋសហព័ន្ធមីយ៉ាន់ម៉ាប្រចាំនៅប្រទេសជប៉ុន | 140-0001 | 4-8-26 Kita-Shinagawa, Shinagawa-ku, Tokyo | 03-3441-9291 | 03-3447-7394 | contact@myanmar-embassy-tokyo.net | ជប៉ុន ភូមា អង់គ្លេស |
| | នៅបរទេស | Department of Labour, The Ministry of Labour, Immigration and Population of the Republic of the Union of Myanmar | (កំពុងបញ្ជាក់) | | | | | |

[យោងៈ “ការទទួលយកពលករបរទេសថ្មី (ការបង្កើតលក្ខណៈសម្បត្តិស្នាក់នៅ ពលករជំនាញ)” ក្នុងគេហទំព័ររបស់ក្រសួងយុត្តិធម៌]
http://www.moj.go.jp/nyuukokukanri/kouhou/nyuukokukanri05_00021.html

# អត្ថប្រយោជន៍នៃការធ្វើការនៅជនបទ (កំរិតចំណាយលើជីវភាពជាដើម)



## ថ្លៃជួលផ្ទះក្នុង១ខែ






* ធ្វើឡើងដោយយោងលើស្ថិតិស្រាវជ្រាវនៃក្រសួងមហាផ្ទៃអំពីផ្ទះនិងដីធ្លី (ឆ្នាំ2013)

## ថ្លៃចំណាយលើជីវភាពក្នុង១ខែ






*ធ្វើឡើងដោយយោងលើស្ថិតិស្រាវជ្រាវនៃក្រសួងមហាផ្ទៃអំពី (ឆ្នាំ2017 ចំណូលចំណាយក្នុង១គ្រួសារតាមស្រុកនៃខេត្តក្រុង) (គ្រួសារទាំងអស់)
*ថ្លៃចំណាយលើជីវភាពជាថ្លៃសរុបនៃថ្លៃហូបចុក ទឹកភ្លើងហ្គាស សំលៀកបំពាក់ ថ្លៃព្យាបាល

## ចំណូលក្នុង១ខែ (ប្រាក់នៅសល់ក្នុងដៃ)

○ ការប្រៀបធៀបថ្លៃជួលផ្ទះទូទាំងប្រទេស
Tokyo (No. 1): 77,174 យ៉េន (1)
Aomori (No. 47): 36,529 យ៉េន
ថ្លៃខុសគ្នា: 40,645 យ៉េន

○ ការប្រៀបធៀបថ្លៃចំណាយទូទាំងប្រទេស
Tokyo (No. 1): 113,557 យ៉េន ...(2)
Yamaguchi (No. 47): 76,385 យ៉េន
Difference: 37,172 យ៉េន



○ **ដោយដកតំលៃខាងលើ (ថ្លៃជួលផ្ទះនិងថ្លៃចំណាយ) គេអាចប៉ាន់ស្មានចំណូលប្រចាំខែ (ប្រាក់នៅសល់ក្នុងដៃ) ក្នុងកំរិតមួយ**

ឧទាហរណ៍ 1 (ទីក្រុង)៖ 228,800 យ៉េន (សំគាល់ 1) (ប្រាក់ខែ) − ((1) (ថ្លៃជួលផ្ទះ) + (2) (ថ្លៃចំណាយ)) = 38,069 yen ( ប្រាក់នៅសល់ក្នុងដៃ )
ឧទាហរណ៍ 2 (ជនបទ)៖ 180,500 យ៉េន (សំគាល់ 1) (ប្រាក់ខែ) − (38,447 yen (សំគាល់ 2) (ថ្លៃជួលផ្ទះ)+86,440 yen (សំគាល់ 3) (ថ្លៃចំណាយ))
= 55,613 yen ( ប្រាក់នៅសល់ក្នុងដៃ )

សំគាល់ 1: ធ្វើឡើងយោងតាម "ស្ថិតិមូលដ្ឋាននៃប្រាក់ឈ្នួលឆ្នាំ2018" នៃក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព។ ប្រាក់ខែអ្នកធ្វើការអាយុ 20-24នៅ Tokyo (No. 1) និង Miyazaki (No. 47)។
សំគាល់ 2: ថ្លៃជួលផ្ទះក្នុង១ខែនៅខេត្ត Miyazaki (No. 41) សំគាល់ 3: ថ្លៃចំណាយក្នុង១ខែនៅខេត្ត Miyazaki (No. 41)។

○ **ការធ្វើការនៅជនបទក៏មានចំណុចល្អបើគិតលើចំណូល ព្រោះថ្លៃជួលផ្ទះនិងថ្លៃចំណាយតិចជាងនៅទីក្រុង។**

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ



## ការណែនាំអំពីសហគ្រាស

- ទីតាំងសហគ្រាស៖ ទីក្រុងតូក្យូ
- ប្រភេទអាជ្ញាប័ណ្ណ ៖ សហគ្រាសសាងសង់សំណង់ស៊ីវិលនិងសាធារណ:
- ទឹកប្រាក់លក់៖ 31.5 ប៊ីលាន (ឆ្នាំសារពើពន្ធ2018)
- ចាប់ផ្តើមទទួលពលករបរទេស៖ ឆ្នាំ2016

(ស្ថិតិចុងខែមករា ឆ្នាំ2019៖ ទទួលយកពលករ4នាក់ កម្មសិក្សាការី36នាក់)

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល

✓ ចំពោះកម្មសិក្សាការីជំនាញដែលមានបទពិសោធន៍នៅជប៉ុនតិច ធ្វើយ៉ាងណាកុំអោយមានការយល់ខុសលើសេចក្តីណែនាំនៅកន្លែងធ្វើការ គឺរៀបចំក្រុម “កម្មសិក្សាការីជំនាញកម្រិត១ឬកម្រិត២ + កម្មសិក្សាការីជំនាញកម្រិត៣ ឬពលករសំណង់ជនបរទេស + អ្នកដឹកនាំជនជាតិជប៉ុន” ដើម្បីអោយកម្មសិក្សាការីសិស្សច្បងអាចជួយមើលប្រាប់អោយការយល់គ្នាបានត្រឹមត្រូវ

✓ នៅអគារស្នាក់នៅគណ:កម្មការគ្រប់គ្រងជាជនជាតិវៀតណាម ធ្វើការប្រជុំមួយខែ1ដង ដើម្បីពិភាក្សារៀបចំបរិស្ថានរស់នៅអោយស្រួលរស់នៅ។ ហើយក្រុមហ៊ុនគាំទ្រចំពោះលទ្ធផលនេះ។ (ការប្តូរជាតិប៉ប៉ននៃម្ហូបអាហារ ការបោសសំអាតជុំវិញ ការសិក្សាភាសាជប៉ុន ការរៀបចំកម្មវិធីជាដើម)

✓ រៀបចំកម្មវិធីដូចជា ដំណើរកំសាន្តដោយរថយន្តក្រុងឬអាំងសាច់នៅនិទាឃរដូវ ពិធីជប់លៀងចុងឆ្នាំ ពិធីទទួលឆ្នាំថ្មីវៀតណាម កម្មវិធីទេសនាប្រដៅដោយជូនជីជាដើម ដើម្បីជំរុញអោយការប្រាស្រ័យទាក់ទងគ្នាមានភាពសកម្មនិងអោយមានការយល់របួចម័គ្នាទៅវិញទៅមក។

## ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

✓ ក្នុងចំណោមកម្មសិក្សាការីជំនាញ មានមនុស្សដែលមានសមត្ថភាពនិងខិតខំ ហើយជាការល្អដែលអាចទទួលបានឱកាសបញ្ចេញសមត្ថភាពដូចជាជំនាញនិងភាសាជប៉ុនដែលទទួលបានក្នុងអំឡុងពេលកម្មសិក្សា ជាបន្តទៀតនៅការដ្ឋានសំណង់ក្នុងប្រទេសជប៉ុន។

✓ ចំពោះអ្នកធ្វើការជំនាញសំណង់ វាជាការលំបាកក្នុងការទទួលបានការទទួលស្គាល់ថាមានជំនាញក្នុងអំឡុងពេលពីរឬបីឆ្នាំ ហេតុដូច្នេះហើយចំពោះជនបរទេសដែលចូលជប៉ុនជាកម្មសិក្សាការីជំនាញគឺសប្បាយចិត្តដែលទទួលបានឱកាសល្អក្នុងការចាប់យកនូវជំនាញកំរិតខ្ពស់មុននឹងត្រឡប់ទៅប្រទេសកំណើតខ្លួនវិញ។

### ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

- រយ:ពេល 4ខែ៖ ចូលរៀនភាសានិងចំណេះដឹងមូលដ្ឋាននៅប្រទេសកំណើតវៀតណាម (ជាកម្មសិក្សាការីមុនចូលប្រទេសជប៉ុន)
- រយ:ពេល1ខែ៖ កម្មវិធីសិក្សាកំណត់ដោយច្បាប់នៅជប៉ុន (ភាសាជប៉ុន ជីវភាពទូទៅ ច្បាប់ទាក់ទងការងារជាដើម)
- 1ខែក្រោយ*៖ ធ្វើការងារសំណង់ទាក់ទងនឹងពុម្ពជាកម្មសិក្សាការីជំនាញ
- 3ឆ្នាំក្រោយ*៖ ប្តូរលក្ខណ:សម្បត្តិស្នាក់នៅទៅជា ពលករសំណង់បរទេស(លក្ខណ:សម្បត្តិស្នាក់នៅ៖ សកម្មភាពពិសេស) បន្តធ្វើការងារពុម្ព
- 4ឆ្នាំក្រោយ*៖~ ជាប្រធានក្រុមនៅការដ្ឋាន ជាអ្នកដឹកនាំកំលាំងវ័យក្មេងប្រហែល 5នាក់

*រយ:ពេលរាប់ចាប់ពីពេលចូលជប៉ុនតំបូងជាកម្មសិក្សាការីជំនាញ

## ការណែនាំអំពីពលករ



បុរសជនជាតិវៀតណាម (29ឆ្នាំ)



[សកម្មភាពការងារផ្គុំពុម្ពដើម្បីបង្ហូរបេតុង]

- បទពិសោធន៍ការងារជាពលករសំណង់បរទេសរយ:ពេល24ខែ
- សញ្ញាប័ត្រដែលមាន៖ វិញ្ញាបនកម្មជំនាញមូលដ្ឋានកម្រិត២ ចូលរួមសិក្ខាសាលាអំពីការងារស្លូច សិក្ខាសាលាអំពីសុវត្ថិភាពនិងអនាម័យសំរាប់អ្នកធ្វើការងារប្រើរណារមូលជាដើម
- ការប្រឡងសមត្ថភាពភាសាជប៉ុន៖ កម្រិតN2
- មានសមត្ថភាពជំនាញខ្ពស់ ទទួលបន្ទុកមេក្រុមការងារនៅការដ្ឋាន
- ពន្យល់ការងារដែលមេការប្រាប់ទៅដល់កម្មសិក្សាការីជំនាញ ហើយក៏មានមុខងារជាអ្នកបង្រៀនភាសាជប៉ុននៅកន្លែងស្នាក់នៅផងដែរ

### សំដីសមីខ្លួន

✓ ការប្រើប្រាស់ភាសាបរទេសធ្វើការនៅពេលទើបមកដល់ជប៉ុនគឺមានការលំបាកខ្លាំង ប៉ុន្តែមិនបានបោះបង់គឺខិតខំរៀនភាសាជប៉ុនរហូតមក

✓ ចង់ប្រើប្រាស់ជំនាញដែលខ្លួនទទួលបាន ហើយបន្តការងារនៅជប៉ុនបន្តទៀត

✓ នៅអនាគតចង់ចូលរួមចំណែកធ្វើអោយសេដ្ឋកិច្ចវៀតណាមរីកចំរើន

### ទិដ្ឋភាពនៃប្រព័ន្ធផ្តល់ប្រាក់កំរៃនៅស្ថាប័នទទួល

- កម្មសិក្សាការីជំនាញឆ្នាំទី1 ប្រហែល16.7មុឺនយ៉េន

↓

- ពលករសំណង់បរទេស ឆ្នាំទី1៖ ប្រហែល19.2មុឺនយ៉េន

(រួមទាំងការវាយតំលៃលើសញ្ញាបត្រនិងអកប្បកិរិយា។ល។)

↓

- ពលករសំណង់បរទេស ឆ្នាំទី2៖ ប្រហែល19.4មុឺនយ៉េន

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ

国土交通省

## ការណែនាំអំពីសហគ្រាស

- ទីតាំងសហគ្រាស៖ ខេត្តឈិបា
- ប្រភេទអាជ្ញាប័ណ្ណ ៖ ជាងឈើ ការងាររន្ទា និងការងារដី
- ទឹកប្រាក់លក់៖ 200 លានយ៉េន (ឆ្នាំសារពើពន្ធ2017)
- ចាប់ផ្តើមទទួលពលករបរទេស៖ ឆ្នាំ2012

(ស្ថិតិចំនួនទទួលយកចុងខែមករា ឆ្នាំ2019៖ ពលករសំណង់បរទេស4នាក់ កម្មសិក្សាការីជំនាញ 8នាក់)

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល

✓ នៅក្នុងក្រុមហ៊ុន មានរបៀបគិតមូលដ្ឋានគឺថា ធនធានមនុស្សបរទេសដូចជាកម្មសិក្សាការីជំនាញ ពលករសំណង់បរទេសជាដើមគឺត្រូវមានភាពស្មើគ្នាជាមួយជនជាតិជប៉ុន ហើយភាគីទាំងអស់ខិតខំនិងគិតថាភាគីទាំងពីរជាមិត្តរួមការងារដែលត្រូវសហការគ្នាទៅវិញទៅមក

✓ ចំពោះពាក្យសព្ទដែលប្រើញឹកញាប់ក្នុងការងារ គឺធ្វើជាតារាងមានអក្សរហ៊ីរ៉ាហ្គាណា អក្សរឡាតាំង ពាក្យអង់គ្លេស ហើយធ្វើតេស្តម្តងហើយម្តងទៀតអោយមានការចងចាំ

✓ តាមរយៈកម្មវិធីរបស់សហគមន៍និងការងារស្ម័គ្រចិត្ត ផ្តល់ឱកាសអោយស្វែងយល់អំពីប្រពៃណីជប៉ុន និងយល់គ្នាទៅវិញទៅមកអោយបានស៊ីជំរៅជាមួយពលរដ្ឋក្នុងសហគមន៍

## ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

✓ តាមរយៈប្រព័ន្ធនេះ ការដែលអាចធ្វើការបានរយៈពេលវែងជាមួយអ្នកបញ្ចប់កម្មសិក្សាការីជំនាញហើយក្លាយជាធនធានមនុស្សមានសមត្ថភាព គឺផ្តល់កំលាំងចិត្តក្នុងការលើកកំពស់កំរិតបច្ចេកទេសទាំងអ្នកបង្រៀននិងអ្នកត្រូវបានគេបង្រៀន។ ហើយនៅក្នុងឧស្សាហកម្មដែលមានការខ្វះកំលាំងពលកម្មធ្ងន់ធ្ងរនេះ មានមេការខ្លះសប្បាយចិត្តព្រោះវាជាសេចក្តីសង្ឃឹមតែមួយគត់ដែលអាចរកមិត្តរួមការងារបាន។

✓ ការទទួលយកតាមប្រព័ន្ធពលករសំណង់បរទេសជាវិធានការបណ្តោះអាសន្នត្រឹមឆ្នាំ2020 ហើយរយៈពេលស្នាក់នៅកំណត់គឺវែងបំផុតត្រឹម3ឆ្នាំ ហើយក្នុងករណីដែលសហគ្រាសនិងសមីខ្លួនប្រាថ្នា បើមានវិធានការទទួលស្គាល់ការស្នាក់នៅជាបន្តទៀតវាជាការល្អ។

## ការណែនាំអំពីពលករ



បុរសជនជាតិហ្វីលីពីន (30ឆ្នាំ)



[សកម្មភាពការងារភ្ជាប់ពុម្ពដែកលើដែកបារមូល (ខាងឆ្វេងគឺធនធានមនុស្សបរទេស)]

- បទពិសោធន៍ការងារជាពលករសំណង់បរទេសរយៈពេល 24ខែ
- សញ្ញាប័ត្រដែលមាន៖ មេការ ផ្សារអគ្គិសនី ការប្រើប្រាស់តង់ស្យុងកំរិតទាប ផ្ទុសំលៀង រណារមូល
- ការប្រឡងសមត្ថភាពភាសាជប៉ុន៖ កម្រិតN3
- ធ្វើការងារទាក់ទងនឹងការតម្លើង ភ្ជាប់ ដោះពុម្ពដែក
- មានបច្ចេកទេសខ្ពស់បើប្រៀបធៀបនឹងអ្នកជំនាញជប៉ុនដែលមានបទពិសោធន៍ប្រហែលគ្នា មានមុខងារជាមេការរងមើលការខុសត្រូវនៅការដ្ឋាន

## សំដីសមីខ្លួន

✓ គោលដៅមុនមកជប៉ុនគឺដើម្បីរកប្រាក់ ប៉ុន្តែឥឡូវគិតថាចង់ប្រើប្រាស់បទពិសោធន៍និងសមត្ថភាពរបស់ខ្លួនអោយមានប្រយោជន៍ចំពោះអ្នកដទៃ

✓ ក្រៅពីការងារ តាមរយៈការចូលរួមសកម្មភាពនៅក្នុងកម្មវិធីនៅកន្លែងសុខមាលភាពសហគមន៍ មានការសប្បាយចិត្តដែលឃើញទឹកមុខញញឹមរបស់អ្នកទាំងអស់គ្នានៅក្នុងសហគមន៍

### ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

- រយៈពេល1ខែ៖ ចូលរៀនភាសានិងចំណេះដឹងមូលដ្ឋាននៃជំនាញនៅប្រទេសកំណើតហ្វីលីពីន (ជាកម្មសិក្សាការីមុនចូលប្រទេសជប៉ុន)
- រយៈពេល1ខែ៖ នៅក្នុងប្រទេសជប៉ុន រៀនអំពីភាសាជប៉ុន ទំនៀមទំលាប់របៀបរស់នៅប្រទេសជប៉ុន(ពិសេសរបៀបបែងចែកសំរាម) ជាដើម
- 2ខែក្រោយ*៖ ធ្វើការងារទាក់ទងនឹងការតម្លើង ភ្ជាប់ ដោះពុម្ពដែកជាកម្មសិក្សាការីជំនាញ
- 3.5ឆ្នាំក្រោយ*៖ ប្តូរលក្ខណៈសម្បត្តិស្នាក់នៅទៅជា ពលករសំណង់បរទេស(លក្ខណៈសម្បត្តិស្នាក់នៅ៖ សកម្មភាពពិសេស) បន្តធ្វើការងារដូចមុន
- 3.8ឆ្នាំក្រោយ*~៖ ជាប្រធានក្រុមរងនៅការដ្ឋាន ជាអ្នកដឹកនាំកំលាំងវ័យក្មេងប្រហែល 4នាក់

*រយៈពេលរាប់ចាប់ពីពេលចូលជប៉ុនតំបូងជាកម្មសិក្សាការីជំនាញ

### ទិដ្ឋភាពនៃប្រព័ន្ធផ្តល់ប្រាក់កំរៃនៅស្ថាប័នទទួល

- កម្មសិក្សាការីជំនាញ ប្រហែល15ម៉ឺនយ៉េន

↓

- ពលករសំណង់បរទេស(សកម្មភាពពិសេស) ឆ្នាំទី1 ប្រហែល 26ម៉ឺនយ៉េន

↓

- ឡើងជាមេការ (រង) ប្រហែល 29ម៉ឺនយ៉េន

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ

## ការណែនាំអំពីសហគ្រាស

- ទីតាំងសហគ្រាស៖ ខេត្តយ៉ាម៉ាហ្គាតា
- ប្រភេទអាជ្ញាប័ណ្ណ ៖ ការងាររន្ទា និងការងារដី
- ទឹកប្រាក់លក់៖ 4.4 ប៊ីលាន (ឆ្នាំសារពើពន្ធ2017)
- ចាប់ផ្តើមទទួលយកធនធានមនុស្សបរទេស៖ ឆ្នាំ2000

(ស្ថិតិចំនួនទទួលយកត្រឹមថ្ងៃទី 31ខែមករា ឆ្នាំ2019៖ ពលករសំណង់បរទេស4នាក់ កម្មសិក្សាការីជំនាញ17នាក់)

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល

- ✓ តាមរយៈកិច្ចសហប្រតិបត្តិការអំពីការបណ្តុះបណ្តាលធនធានមនុស្សជាដើមជាមួយក្រុមហ៊ុនសំណង់នៅវៀតណាម គឺអាចសម្រេចនូវការបណ្តុះបណ្តាលធនធានមនុស្សបរទេសនិងការវាយតំលៃបុគ្គលិកបានយ៉ាងល្អិតល្អន់ តាមរយៈការបង្ហាញអោយឃើញនូវផែនការនៃអាជីពមុននិងក្រោយចូលប្រទេសជប៉ុន និងការផ្តល់ប្រាក់លើកទឹកចិត្តចំពោះការទទួលបានសញ្ញាប័ត្រជាដើម ធ្វើការជំរុញកំលាំងចិត្តកម្មសិក្សាជំនាញនិងការប្រឡងយកសញ្ញាប័ត្រ
- ✓ អោយធនធានមនុស្សបរទេសចូលរួមក្នុងកម្មវិធីប្រកួតប្រជែងជំនាញក្នុងក្រុមហ៊ុន ហើយអ្នកដែលមានសមត្ថភាពផ្តល់មុខងារជាអ្នកដឹកនាំក្រុមជាដើម គឺផ្តល់អត្ថប្រយោជន៍ដូចគ្នាជាមួយអ្នកមានជំនាញជនជាតិជប៉ុន
- ✓ ជាប្រាក់ឧបត្ថម្ភសុខមាលភាព តាមរយៈការរៀបចំកន្លែងស្នាក់នៅគឺកាត់បន្ថយចំណាយលើការស្នាក់នៅ មានប្រព័ន្ធត្រឡប់ទៅប្រទេសរយៈពេលប្រហែល1សប្តាហ៍ ហើយផ្តល់ថ្លៃធ្វើដំណើរដល់ពលករសំណង់បរទេស

## ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

- ✓ យោងលើចំណុចដែលទទួលបានសម្ថភាពជំនាញសំណង់កំរិតខ្ពស់ ទទួលបានសញ្ញាប័ត្រប្រឡងជំនាញកម្រិត1 ប័ណ្ណបើកបររថយន្តធុនធំ យល់អំពីវប្បធម៌ គ្នាទៅវិញទៅមក យើងគិតថាការដែលមានប្រព័ន្ធទទួលស្គាល់រយៈពេលស្នាក់នៅបន្ថែមលើរយៈពេល (3~5ឆ្នាំ)នៃកម្មសិក្សាជំនាញ ជាការល្អ។
- ✓ ផ្អែកលើចក្ខុវិស័យបណ្តុះបណ្តាលជំនាញរបស់សហគ្រាសទទួល និងចក្ខុវិស័យលើកកំពស់កំលាំងចិត្តធ្វើការរបស់ធនធានមនុស្សបរទេស វាជាចំណុចសំខាន់ដែលអាចដៅផែនការនៃអាជីពមុននិងក្រោយចូលប្រទេសជប៉ុន

## ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

- រយៈពេល3ខែ៖ ចូលរៀនភាសានិងចំណេះដឹងមូលនិងរៀនជំនាញសំណង់នៅក្រុមហ៊ុនសំណង់នៅប្រទេសកំណើតវៀតណាម (ជាកម្មសិក្សាការីមុនចូលប្រទេសជប៉ុន)
- រយៈពេល1ខែ៖ ចូលរៀនរួមគ្នានៅក្នុងប្រទេសជប៉ុនអំពីភាសាជប៉ុននិងចំណេះដឹងមូលដ្ឋានអំពីជីវភាពរស់នៅជប៉ុន
- 1ខែក្រោយ*៖ ធ្វើការងារទាក់ទងនឹងការបូមបេតុងជាកម្មសិក្សាការីជំនាញ
- 3ឆ្នាំក្រោយ*: ៖ ត្រឡប់ទៅក្រុមហ៊ុនសំណង់នៅប្រទេសវិញ ធ្វើការងារទាក់ទងនឹងការបូមបេតុង យកបានប័ណ្ណបើកបររថយន្តធុនធំ ក្លាយជាអ្នកប្រតិបត្តិការ
- 5ឆ្នាំក្រោយ*៖ ប្តូរលក្ខណ:សម្បត្តិស្នាក់នៅទៅជា ពលករសំណង់បរទេស(លក្ខណ:សម្បត្តិស្នាក់នៅ៖ សកម្មភាពពិសេស) បន្តធ្វើការងារដូចមុន
- ចាប់ពី5ឆ្នាំក្រោយ* ៖ជាអ្នកដឹកនាំកម្មសិក្សាការីប្រហែល 5ទៅ 8នាក់ ជាប្រធានក្រុមរងនៅការដ្ឋានធ្វើការជាមួយពលករនៃក្រុមហ៊ុនផ្សេង

*រយៈពេលរាប់ចាប់ពីពេលចូលជប៉ុនតំបូងជាកម្មសិក្សាការីជំនាញ

## ការណែនាំអំពីពលករ



បុរសជនជាតិវៀតណាម (29ឆ្នាំ)



[សកម្មភាពការងារបាញ់បេតុងចូលពុម្ពដោយប្រើរថ

- បទពិសោធន៍ការងារជាពលករសំណង់បរទេសរយៈពេល 31ខែ
- សញ្ញាប័ត្រដែលមាន៖ ការប្រឡងជំនាញកម្រិត3 (កម្រិត2បានជាប់រួចហើយ)
- ការប្រឡងសមត្ថភាពភាសាជប៉ុន៖ កម្រិតN2
- ធ្វើការងារទាក់ទងនឹងការបាញ់បេតុងនៅដោយប្រើម៉ូទ័រ
- មានជំនាញនិងសមត្ថភាពភាសាជប៉ុនខ្ពស់ ជាមេការងជួយដល់ការងារប្រជុំនៅការដ្ឋាន ធ្វើការងារដឹកនាំកម្មសិក្សាការីជំនាញជាដើមផងដែរ

## សំដីសមីខ្លួន

- ✓ មានគោលដៅរៀនជំនាញនិងភាសាជប៉ុន ដើម្បីឈានដល់កំរិតមេការ
- ✓ ចង់ក្លាយជាមេដឹកនាំល្អរបស់កម្មសិក្សាការីជំនាញដែលធ្វើការជាមួយគ្នា
- ✓ ចង់រៀនសូត្រអំពីវប្បធម៌ជប៉ុននិងផ្សព្វផ្សាយអំពីវប្បធម៌វៀតណាម

## ទិដ្ឋភាពនៃប្រព័ន្ធផ្តល់ប្រាក់កំរៃនៅស្ថាប័នទទួល

កម្មសិក្សាការីជំនាញ ឆ្នាំទី1៖ ទឹកប្រាក់ផ្តល់ជាមធ្យម 24.5ម៉ឺនយ៉េន (ប្រាក់ខែគោល 14.8ម៉ឺនយ៉េន)
ពលករសំណង់បរទេសឆ្នាំទី1៖ ទឹកប្រាក់ផ្តល់ជាមធ្យម 31.5ម៉ឺនយ៉េន (ប្រាក់ខែគោល 16.6ម៉ឺនយ៉េន)
ពលករសំណង់បរទេសឆ្នាំទី3៖ ទឹកប្រាក់ផ្តល់ជាមធ្យម 34.0ម៉ឺនយ៉េន (ប្រាក់ខែគោល 17.0ម៉ឺនយ៉េន+ ថ្លៃសញ្ញាប័ត្រ0.7ម៉ឺនយ៉េន)

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ

**ការណែនាំអំពីសហគ្រាស**

- ឈ្មោះសហគ្រាស៖ ក្រុមហ៊ុនផលិតនាវាA
- ទីតាំង ៖ តំបន់ស៊ិកុគុជាដើម
- ប្រទេសកំណើតរបស់ពលករបរទេស ៖ ចិន

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល - ផ្ដល់កន្លែងរស់នៅជនបទមានផាសុខភាព

✓ បង្កើតកន្លែងស្នាក់នៅថ្មីសម្រាប់អោយស្នាក់នៅ។ ប្រើប្រាស់លក្ខណ:ពិសេសនៃជនបទដែលដីធំទូលាយ ផ្ដល់ទីកន្លែងដែលមានភាពសម្បូរបែបដោយតំលៃថោក។

- បន្ទប់ដាច់ដោយឡែកដែលមានទំហំ 6តាតាមិ។ រៀបចំប្រព័ន្ធអ៊ិនធឺណែតដែលអាចទាក់ទងជាមួយគ្រួសារបាន។ អាហារថ្លៃត្រង់មិនអស់ថ្លៃ អាចដាំស្លខ្លួនឯងបាន។
- រៀបចំអោយមានសាលលេងប៉េងប៉ុង បន្ទប់បុកប៊ីយ៉ែ បន្ទប់ហាត់ប្រាណដែលអាចកំសាន្តជាមួយមិត្តភក្តិបាន។
- ផ្ដល់កន្លែងស្នាក់នៅដែលមានបរិក្ខារទាំងនេះក្នុងតំលៃ 15,000យ៉េន/ខែ។

✓ ជាទីតាំងដែលមានភាពងាយស្រួល

- ជាទីតាំងល្អដែលចំណាយពេលដើរត្រឹម10នាទីទៅដល់ផ្សារខ្នាតធំ ដូច្នេះទោះជាគ្មានរថយន្តក៏គ្មានការលំបាកដល់ជីវភាព។
- មានទីធ្លានៅក្បែរ។ អាចលេងបាល់ទាត់ឬបាល់បោះបាន។

✓ បរិស្ថានដូចនៅផ្ទះ

- មានកម្មវិធីដូចជាដំណើរកំសាន្តបុគ្គលិក កម្មវិធីជប់លៀងនៅរដូវក្ដៅ។ • នៅរដូវចូលឆ្នាំចិន បុណ្យសែនព្រះខែមានការចែកកាដូ។

✓ ការគាំទ្រជីវភាពដ៏ម៉ត់ចត់

- មានអ្នកបកប្រែប្រចាំ24ម៉ោង នៅចាំទំនុកបំរុងផ្នែកជីវភាពកុំអោយមានបញ្ហា។
- ចេញព្រឹត្តិប័ត្រក្នុងក្រុមហ៊ុនសំរាប់កម្មសិក្សាការី1ខែម្ដង។(ព័ត៌មានអំពីប្រទេសជប៉ុន ប្រទេសចិនជាដើម)



ចង្ក្រានដែលអាចដាំស្លបាន



នៅកន្លែងស្នាក់នៅមានសាលលេងប៉េងប៉ុង បន្ទប់បុកប៊ីយ៉ែ បន្ទប់ហាត់ប្រាណ



បន្ទប់ដាច់ដោយឡែកយ៉ាងស្អាត



ការបង្រៀនសុជីវធម៌សំរាប់ការជិះកង់



ដំណើរកំសាន្តរីលល្វាច(USJ)



កន្លែងស្នាក់នៅថ្មីធ្វើសំរាប់ជនបរទេស(មើលពីខាងក្រៅ)

## សំដីរបស់ជនជាតិចិនធ្វើការនៅក្រុមហ៊ុនផលិតនាវាA

✓ ខ្ញុំធ្វើការងារផ្សារនៅរោងចក្រធ្វើនាវា។ ដោយសារមានការណែនាំពីសិស្សច្បង ឥឡូវនេះខ្ញុំអាចធ្វើម្នាក់ឯងបានស្ទើរគ្រប់ការងារ។

✓ នេះជាកន្លែងស្នាក់នៅរបស់យើង។ គឺរស់នៅប្រកបដោយផាសុខភាព។

✓ នៅថ្ងៃសំរាកយើងហាត់ប្រាណនៅសាលវាយប៉េងប៉ុងនិងបន្ទប់ហាត់ប្រាណ។

✓ យើងទទួលបានឯកសណ្ឋាននិងអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ ជាការល្អណាស់។

✓ ថ្លៃស្នាក់នៅគឺ15,000យ៉េនរួមទាំងថ្លៃទំនាក់ទំនងនិងថ្លៃទឹកភ្លើង ហើយផ្ញើប្រាក់ខែភាគច្រើនទៅប្រទេស។



ពិធីជប់លៀងនៅកន្លែងស្នាក់នៅ



ទិដ្ឋភាពនៃការផ្សារ

### ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

✓ រយ:ពេល1ខែ៖ រៀនភាសាជប៉ុន ចំណេះដឹងមូលដ្ឋាននៅប្រទេសកំណើត
✓ រយ:ពេល1ខែ៖ រៀននៅក្នុងប្រទេស
✓ រយ:ពេល1ខែ៖ ធ្វើការងារផ្សារក្នុងនាមជាកម្មសិក្សាការីជំនាញ
✓ 36ខែក្រោយ៖ ធ្វើការងារជាពលករក្នុងសកម្មភាពកំណត់គឺធ្វើនាវា
✓ 24ខែក្រោយ៖ ជាមេក្រុមដឹកនាំកំលាំងវ័យក្មេង10នាក់
✓ អនាគត៖ នឹងត្រឡប់មកជប៉ុនវិញជាពលករជំនាញកម្រិត១

### ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

✓ ចំពោះក្រុមហ៊ុនយើងដែលបានចូលស៊ប់ក្នុងគំរោងធ្វើនាវាដឹកកុងតឺន័រធំបំផុតក្នុងលោក សកម្មភាពកំណត់ធ្វើនាវានេះគឺជាប្រព័ន្ធដែលចូលរួមចំណែកជំរុញធ្វើអោយការផលិតមានភាពរលូននិងមានលំនឹង។ ជាលទ្ធផលវាក៏ផ្សារភ្ជាប់ដល់លំនឹងការងាររបស់ជនជាតិជប៉ុនផងដែរ។

✓ ប្រព័ន្ធថ្មី"ពលករជំនាញ" នឹងទទួលបានការស្វាគមន៍ពីកម្មសិក្សាការីជំនាញបរទេសជាដើម ព្រោះអាចរៀនជំនាញកំរិតខ្ពស់ក្នុងរយ:ពេលវែងនៅប្រទេសជប៉ុនដែលមានបច្ចេកទេសរីកចំរើន។

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ

国土交通省

**ការណែនាំអំពីសហគ្រាស**

- ឈ្មោះសហគ្រាស៖ ក្រុមហ៊ុនផលិតនាវាB
- ទីតាំង ៖ តំបន់គ្យូស៊ូជាដើម
- ប្រទេសកំណើតរបស់ពលករបរទេស ៖ វៀតណាម

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល
## - <u>ការរៀបចំបរិស្ថានការងារដ៏សម្បូរបែបនៅតំបន់ជនបទ</u>

✓ ការណែនាំអំពីសុវត្ថិភាពនិងជំនាញយ៉ាងដិតដល់

- បុគ្គលិកពេញម៉ោងបកប្រែភាសាជួយណែនាំផ្នែកសុវត្ថិភាព ដើម្បីអោយអ្នកធ្វើការជនជាតិវៀតណាមអាចធ្វើការបាន ដោយសុវត្ថិភាពគ្មានការបារម្ភ។
- មិនត្រឹមតែអ្នកបច្ចេកទេសជនជាតិជប៉ុននោះទេ ពលករដែលជាសិស្សច្បងជនជាតិវៀតណាមរួមចំណែកជួយណែនាំ បានយ៉ាងល្អិតល្អន់។ សិស្សច្បងមានទំនួលខុសត្រូវនិងចិត្តមោះមុត កម្មសិក្សាការីអាចធ្វើការងារបានដោយមិនបារម្ភ។

✓ ការចាប់យកភាសាជប៉ុន

- ដាក់បុគ្គលិកបកប្រែភាសាជនជាតិវៀតណាមពេញម៉ោងនៅកន្លែងធ្វើការនិមួយៗ ដើម្បីជួយបង្រៀនភាសាជប៉ុន។
- ដើម្បីជំរុញអោយខំប្រឹងដោយខ្លួនឯង រៀបចំប្រព័ន្ធផ្តល់ប្រាក់លើកទឹកចិត្តដែលទទួលបានសញ្ញាប័ត្រភាសាជប៉ុន។
- អនុវត្តការបង្រៀនភាសាជប៉ុនរយ:ពេល 6ខែមុនមកជប៉ុន ដល់កម្មសិក្សាការីទាំងអស់ដែលសហគ្រាសទទួលបន្ទុកលើចំណាយ។

✓ តាមដានស្ថានភាពការងារ។ល។

- អនុវត្តការសម្ភាសន៍ជាមួយបុគ្គលិកក្រុមហ៊ុនជាប្រចាំ (រៀងរាល់ 3ខែ)
- បុគ្គលិកបកប្រែភាសាជនជាតិវៀតណាមពេញម៉ោងឆ្លើយតបយ៉ាងដិតដល់នឹងការពិគ្រោះទាក់ទងនឹងជីវភាពនិងកន្លែងធ្វើការ

✓ កន្លែងធ្វើការនៅជិតកន្លែងស្នាក់នៅ

- នៅជនបទហើយកន្លែងស្នាក់នៅនៅជិតកន្លែងធ្វើការគឺមានភាពងាយស្រួល។
- ផ្តល់កន្លែងស្នាក់នៅដោយយកថ្លៃតិច និងអោយខ្ចីកង់ដោយមិនគិតប្រាក់សំរាប់ជិះទៅធ្វើការជាដើម។



ការសម្ភាសន៍ជាមួយបុគ្គលិកក្រុមហ៊ុន



កម្មសិក្សាការីកំពុងរៀនអំពីសុវត្ថិភាព



កន្លែងស្នាក់នៅជិតរោងចក្រ (រូបខាងក្រៅ)

## សំដីរបស់ជនជាតិវៀតណាមធ្វើការនៅក្រុមហ៊ុនផលិតនាវាB

✓ ខ្ញុំធ្វើការងារផ្សារជាពលករក្រោមសកម្មភាពកំណត់ផ្នែកធ្វើនាវា។ ខ្ញុំមានបទពិសោធន៍កម្មសិក្សានៅក្រុមហ៊ុនB ទើបការងារដូចបច្ចុប្បន្ននេះខ្ញុំអាចស៊ាំយ៉ាងឆាប់។

✓ បើមានកន្លែងណាមិនយល់ អ្នកណែនាំនៅការដ្ឋានជួយប្រាប់យ៉ាងម៉ត់ចត់តាមរយ:អ្នកបកប្រែ។

✓ នៅក្នុងការសម្ភាសន៍បុគ្គលិកក្រុមហ៊ុនធ្វើការពិគ្រោះដោយយកចិត្តទុកដាក់ ជាការមានប្រយោជន៍។

✓ សមត្ថភាពភាសាជប៉ុនកើនឡើងបន្តិចម្តងៗ មានពេលខ្លះក៏ជួយមើលកម្មសិក្សាការីសិស្សប្អូនដែរ។

✓ កន្លែងស្នាក់នៅត្រូវបានរៀបចំយ៉ាងស្អាត តំលៃ2ម៉ឺនយ៉េនរួមទាំងថ្លៃទំនាក់ទំនងថ្លៃទឹកភ្លើងផង។ នៅជិតកន្លែងធ្វើការហើយរស់នៅដោយផាសុខភាព។

✓ ក្រុមហ៊ុនអោយខ្ចីកង់ដោយមិនគិតថ្លៃ ដែលផ្តល់ការងាយស្រួលក្នុងការទៅទិញអីវ៉ាន់និងទេសចរណ៍។

## ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

✓ រយ:ពេល6ខែ៖ រៀនភាសាជប៉ុន ចំណេះដឹងមូលដ្ឋាននៅប្រទេសកំណើត
✓ រយ:ពេល2ខែ៖ រៀននៅជប៉ុនអំពីជំនាញ សុវត្ថិភាព ជីវភាពរស់នៅជប៉ុនជាដើម
✓ 2ខែក្រោយមកដល់ជប៉ុន៖ ធ្វើការងារផ្សារនៅការដ្ឋានជាដើមក្នុងនាមជាកម្មសិក្សាការីជំនាញ
✓ នៅពេលបញ្ចប់កម្មសិក្សាកម្រិត១និងកម្រិត២(សរុប36ខែ)៖ ប្រឡងកម្រិតជំនាញនៃការប្រឡងវាយតំលៃជំនាញផ្សារ
✓ ត្រឡប់ទៅប្រទេសមួយរយ: និងត្រឡប់ចូលមកជប៉ុនវិញ៖ ធ្វើការជាពលករក្រោមសកម្មភាពកំណត់ផ្នែកធ្វើនាវា
✓ ក្រោយបញ្ចប់សកម្មភាពកំណត់៖ ធ្វើការជាពលករជំនាញកម្រិត១ (គំរោង) (ក្រោមការវាយតំលៃរួមអាចក្លាយជាប្រធានក្រុម)

## ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

✓ តាមរយ:សកម្មភាពកំណត់ផ្នែកធ្វើនាវា ធនធានមនុស្សបរទេសអាចប្រើប្រាស់ជំនាញដែលទទួលបានក្នុងកម្មសិក្សាទៅអនុវត្តជាក់ស្តែង ហើយក៏ជាប្រព័ន្ធដែលមានប្រយោជន៍ចំពោះការដ្ឋានរបស់សហគ្រាសទទួលដែលមានការលំបាកក្នុងការរកកំលាំងពលកម្ម។

✓ ក្រោមប្រព័ន្ធទទួលថ្មី"ពលករជំនាញ" នឹងមានអ្នកមានសមត្ថភាពក្លាយជាអ្នកដឹកនាំដែលអាចបង្រៀនការងារ ឬធ្វើជាប្រធានក្រុមបាន។ តាមរយ:ការលើកកម្ពស់សមត្ថភាពបន្ថែមទៀត គេអាចសង្ឃឹមថាអាចចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ឧស្សាហកម្មប្រទេសកំណើតរបស់ខ្លួននិងឧស្សាហកម្មប្រទេសជប៉ុនផងដែរ។

# គំរូនៃសកម្មភាពធ្វើឡើងដោយសហគ្រាសទទួលឈានមុខ



**ការណែនាំអំពីសហគ្រាស**

- ឈ្មោះសហគ្រាស៖ ក្រុមហ៊ុនផលិតនាវាC
- ទីតាំង ៖ តំបន់ឈីហ្គុគុ
- ប្រទេសកំណើតរបស់ពលករបរទេស ៖ ហ្វីលីពីន

## សកម្មភាពនិងការច្នៃប្រឌិតនៃសហគ្រាសទទួល

**- ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ដោយប្រើប្រាស់ចំណុចខ្លាំងរបស់សហគ្រាសក្នុងសហគមន៍**

✓ អោយពេលទំនេរមានន័យ

・កម្មវិធីដូចជាការជួបជុំពេលបុណ្យណូអែល ការប្រកួតបាល់បោះ ការដើរកំសាន្តនៅសួន ធ្វើយ៉ាងណាអោយសប្បាយនឹងជីវភាពរស់នៅជប៉ុន។ ទំនាក់ទំនងរវាងយជនបរទេសដូចគ្នានិងជនបរទេសជាមួយជនជាតិជប៉ុនកាន់តែជិតស្និទ្ធ ដែលផ្សារភ្ជាប់ដល់ការមានក្រុមការងារល្អ។

・រៀបចំតារាងលេងបាល់បោះដែលមានប្រជាប្រិយនៅប្រទេសកំណើតរបស់កម្មសិក្សាការី។

✓ សកម្មភាពប្រាស្រ័យទាក់ទងជាមួយសហគមន៍

・ប្រើប្រាស់ភាពខ្លាំងក្នុងនាមជាសហគ្រាសនៃសហគមន៍ ចូលរួមក្នុងកម្មវិធីផ្សេងៗរបស់សហគមន៍ ដូចជាកម្មវិធីកីឡា ពិធីបុណ្យ ពិធីបាញ់កាំជ្រួច ពិធីរត់កីឡាម៉ារ៉ាតុនជាដើម។ តាមរយៈសកម្មភាពទាំងនេះ ធ្វើអោយមានការយោគយល់គ្នាបានស៊ីជម្រៅជាមួយពលរដ្ឋក្នុងសហគមន៍ ដែលផ្សារភ្ជាប់ដល់ការបង្កើតបរិស្ថានរស់នៅមានផាសុខភាព។

✓ ការគាំទ្រជីវភាពអោយបានជិតដល់

・តម្លើងប្រព័ន្ធ WI-FI ដោយមិនគិតប្រាក់ដើម្បីអោយងាយស្រួលទាក់ទងជាមួយគ្រួសារនៅប្រទេសកំណើត។

・អនុវត្តការសម្ភាសន៍ជាប្រចាំនៅក្រុមហ៊ុន កន្លែងធ្វើការ ការពិគ្រោះជាភាសាកំណើត ដើម្បីកាត់បន្ថយបន្ទុកដល់ជីវភាពរស់នៅក្រៅប្រទេស។



រៀបចំតារាងបាល់បោះ



ការចូលរួមកម្មវិធីរបស់សហគមន៍



ការចូលរួមសកម្មភាពសំអាតក្នុងសហគមន៍

## សំដីរបស់ជនជាតិហ្វីលីពីនធ្វើការនៅក្រុមហ៊ុនផលិតនាវាC

✓ **ខ្ញុំមានអារម្មណ៍ថាការងារគឺសប្បាយ។**

✓ **បើសិនជាអាច ខ្ញុំគិតថាចង់នៅធ្វើការនៅប្រទេសជប៉ុនយូរជាងនេះទៀត (ប្រហែល5ឆ្នាំ)។**

✓ **បរិស្ថានរស់នៅនៃកន្លែងស្នាក់នៅមានភាពពេញលេញ។ មាន Wireless Lan ដែលអាចអោយទាក់ទងទៅគ្រួសារនៅប្រទេសកំណើតពេលណាក៏បាន។**

✓ **នៅជាប់រោងចក្រមានតារាងបាល់បោះដែលជាបរិក្ខាររបស់ក្រុមហ៊ុន។ នេះជាការល្អណាស់ព្រោះជនជាតិហ្វីលីពីនចូលចិត្តលេងបាល់បោះណាស់។**

✓ **ប្រទេសជប៉ុនមានច្បាប់ទំលាប់ត្រឹមត្រូវ ដែលអាចរស់នៅបានដោយគ្មានការបារម្ភ។**

✓ **ថ្លៃស្នាក់នៅគឺថោកត្រឹម18,000យ៉េនរាប់បញ្ចូលទាំងថ្លៃទឹកភ្លើង ហើយខ្ញុំអាចសន្សំប្រាក់ដើម្បីគ្រួសារ។**

✓ **ឯកសណ្ឋានធ្វើការ ខោអាវរងារ ស្បែកជើងសុវត្ថិភាពជាដើមគឺក្រុមហ៊ុនផ្តល់អោយ។**

### ឧទាហរណ៍នៃប្រវត្តិអាជីពនៅស្ថាប័នទទួល

✓ មុនចូលជប៉ុនរយ:ពេល 2ខែ៖ រៀនភាសាជប៉ុន ចំណេះដឹងមូលដ្ឋាននៅប្រទេសកំណើត
✓ រយ:ពេល1ខែក្រោយចូលជប៉ុន៖ រៀននៅជប៉ុនអំពីទំនៀមទំលាប់រស់នៅ និងភាសាជប៉ុន
✓ ក្រោយការសិក្សាខាងលើ៖ ធ្វើការងារលាបថ្នាំក្នុងនាមជាកម្មសិក្សាការី
✓ ក្រោយ36ខែ៖ ធ្វើការជាអ្នកលាបថ្នាំមានជំនាញខ្ពស់ជាកម្មសិក្សាការីកម្រិត៣ (គំរោង)

### ការវាយតំលៃរបស់សហគ្រាសទទួលលើប្រព័ន្ធទទួលយកពលករសំណង់បរទេស

✓ ក្នុងចំណោមកម្មសិក្សាការីមានអ្នកមានសមត្ថភាពច្រើន ការដែលមានប្រព័ន្ធអោយប្រើប្រាស់អ្វីដែលបានរៀនសូត្រក្នុងកម្មសិក្សាបន្តទៅទៀត ជាការចង់បានរបស់ធនធានមនុស្សបរទេសនិងសហគ្រាស។

✓ ដោយសារឧស្សាហកម្មធ្វើនាវាមានកន្លែងលំបាកក្នុងការចាប់យកបច្ចេកទេសក្នុងអំឡុងពេលពីរឬបីឆ្នាំ កម្មសិក្សាក្នុងរយ:ពេលវែងជាឱកាសចាប់យកអោយបាននូវបច្ចេកទេសដែលមានកម្រិតខ្ពស់ជាងនេះ។

# គំរូល្អនៃការទទួលកម្មសិក្សាការីជំនាញបរទេសផ្នែកកសិកម្ម

MAFF

## ការចិញ្ចឹមគោយកទឹកដោះ

[ទិដ្ឋភាពទូទៅនៃស្ថាប័នទទួលយក ] (ត្រឹមខែវិច្ឆិកា ឆ្នាំ2018)

ទីកន្លែង៖ ហុកកៃដូ

ចំនួនបុគ្គលិក៖ ពេញសិទ្ធិ8នាក់ កម្មសិក្សាការីជំនាញ4នាក់ អ្នកធ្វើការក្រៅម៉ោងជាដើម4នាក់

ទំហំអាជីវកម្ម៖ គោយកទឹកដោះ980ក្បាល

(បរិមាណទឹកដោះគោឆៅផលិតក្នុង១ឆ្នាំ ប្រអប់1លីត្រប្រហែល 5លានដប)

[ស្ថានភាពនៃកម្មសិក្សាការី]

ចាប់ផ្តើមទទួលយក៖ ខែមិថុនា ឆ្នាំ2015 (មកពីប្រទេសហ្វីលីពីន)

បច្ចុប្បន្ននេះជាស្ត្រីទាំងអស់ អាយុខ្ទង់ 20 ប្រាក់កំរៃទទួលដល់ដៃប្រហែល 13ម៉ឺនយ៉េន

[សកម្មភាពរបស់ស្ថាប័នទទួល]

- នៅពេលជ្រើសរើសទៅសម្ភាសន៍ដល់ទីតាំងផ្ទាល់
- រៀបផ្ទះស្នាក់នៅរបស់កម្មសិក្សាការី (2អគារសំរាប់ 6នាក់) (ថ្លៃរៀបចំប្រហែល 50 លានយ៉េន)
- ក្រោមទ្រឹស្តីថា "រាប់អានដូចគ្រួសារ" នៅថ្ងៃសំរាក នាំទៅដើរកំសាន្ត ពិធីជប់លៀងជាដើម



កម្មសិក្សាការី (ខាងស្តាំ)បាននិយាយថា "ប្រាក់បៀវត្សថ្លៃ កន្លែងស្នាក់នៅក៏មានផាសុខភាព តាមរយៈការផ្ញើប្រាក់ទៅផ្ទះគ្រួសារបានទិញត្រាក់ទ័រនិងម៉ូតូ"



កន្លែងស្នាក់នៅរបស់កម្មសិក្សាការី មានចង្ក្រាន បន្ទប់ទទួលភ្ញៀវ 8តាតាមិ បន្ទប់គេង បន្ទប់ងូតទឹក បង្គន់



ដាក់ទង់ជាតិជប៉ុននិងទង់ជាតិរបស់កម្មសិក្សាការីគឺហ្វីលីពីននៅពីមុខការិយាល័យ

## ការធ្វើចំការ - ដាំបន្លែ

[ទិដ្ឋភាពទូទៅនៃស្ថាប័នទទួលយក] (គិតត្រឹមខែមករា ឆ្នាំ2019)

ទីកន្លែង៖ ខេត្តកាហ្គាវ៉ា

ចំនួនបុគ្គលិក៖ ពេញសិទ្ធិ4នាក់ កម្មសិក្សាការីជំនាញ10នាក់ អ្នកធ្វើការក្រៅម៉ោងជាដើម2នាក់

ទំហំអាជីវកម្ម៖ 55ហិចតា (សាឡាត់ ខ្ទឹម។ល។)

ការធ្វើការយ៉ាងសកម្មរបស់កម្មសិក្សាការីឥណ្ឌូនេស៊ីនៅចំការសាឡាត់ក្រោមការដឹកនាំរបស់ថៅកែ (កណ្តាល)



[ស្ថានភាពនៃកម្មសិក្សាការី ការផ្តួចផ្តើមរបស់ស្ថាប័នទទួល។ល។]

- ចាប់ផ្តើមទទួលយកនៅឆ្នាំ2004 (មកពីឥណ្ឌូនេស៊ី)
- ប្រព័ន្ធបុគ្គលិក ការតំលើងប្រាក់ខែជាដើមគឺដូចគ្នានឹងបុគ្គលិកពេញសិទ្ធិជនជាតិជប៉ុន
- អោយកម្មសិក្សាការីនារី (ឆ្នាំទី3) ធ្វើជាអ្នកទទួលខុសត្រូវផ្នែកផលិត
- ពង្រីកទំហំអាជីវកម្មក្រោយទទួលយក សម្រេចបានការគ្រប់គ្រងការងារមានលក្ខណ:ប្រសើរ
- ទឹកប្រាក់លក់មានទំហំ10ដងនៃទឹកប្រាក់មុនពេលទទួល

[ការផ្តួចផ្តើមរបស់ស្ថាប័នទទួល ស្ថាប័នគ្រប់គ្រង សហគមន៍ក្នុងតំបន់]

- អតីតកម្មសិក្សាការីជំនាញរបស់ស្ថាប័នទទួលដែលបានត្រឡប់ទៅប្រទេសឥណ្ឌូនេស៊ីវិញ បានបង្កើតស្ថាប័នបញ្ជូន ហើយសហការគ្នា
- កសិករនៅក្នុងសហគមន៍ 20គ្រួសារបានរួមគ្នាបង្កើតសមាគមគ្រប់គ្រងដោយខ្លួនឯងនៅឆ្នាំ 2011
- ជំរុញអោយចូលរួមក្នុងកម្មវិធីរបស់សហគមន៍ នៅពិធីបុណ្យច្រៀងចំរៀងឥណ្ឌូនេស៊ីជាដើម ធ្វើអោយមានចំណុចប្រសព្វគ្នាជាមួយសហគមន៍